# កំណត់អ្នកបោះពុម្ពផ្សាយ

ចម្វាក់ប្រាក់គឺជាផ្នែកមួយក្នុងវិស័យចម្វាក់ផ្សេងៗនៃសិល្បៈប្រពៃណីខ្មែរ។ ការប្រើប្រាស់គ្រឿងប្រាក់ក្នុងសង្គមខ្មែរ ឃើញថាគេឲ្យតម្លៃជាទូទៅតាំងពីអ្នកស្រុកធម្មតារហូតដល់អ្នកមានបណ្តាសក្តិ នាម៉ឺន មន្ត្រី និងព្រះមហាក្សត្រជាដើមផង។ ដូច្នេះវិស័យនេះមានសារសំខាន់ណាស់ដែរ ទើបអង្គការយូណេស្កូប្រចាំប្រទេសកម្ពុជា និងវិទ្យាស្ថានវ៉េយំសហការគ្នាធ្វើកិច្ចការនេះឡើងដោយមានលោក គង់ វីរៈ ជាអ្នកស្រាវជ្រាវផ្ទាល់។

ក្រោយពីធ្វើការងារនេះមួយរយៈមកយើងយល់ឃើញថា លទ្ធផលស្រាវជ្រាវនេះមានសារសំខាន់ ហើយគួរតែផ្សព្វផ្សាយឲ្យបានជ្រួតជ្រាបដល់សាធារណជនទូទៅ ទើបវិទ្យាស្ថានវ៉េយំសម្រេចបោះពុម្ពផ្សាយជាសៀវភៅអំពីគ្រឿងប្រាក់ខ្មែរនេះឡើង។

ក្នុងឱកាសនេះ យើងសូមថ្លែងអំណរគុណចំពោះអង្គការយូណេស្កូ (UNESCO) ដែលឧបត្ថម្ភការស្រាវជ្រាវ, លោក គង់ វីរៈ ដែលបានធ្វើការស្រាវជ្រាវ, ជាងចម្វាក់ប្រាក់ និងលោកអ្នកដែលជួយផ្តល់ពត៌មានផ្សេងៗ។ យើងក៏សូមថ្លែងអំណរគុណចំពោះ មូលនិធិរ៉ុកហ្វេល័រ (The Rockefeller Foundation) ដែលបានជួយឧបត្ថម្ភក្នុងការបោះពុម្ពសៀវភៅនេះឡើង។

ភ្នំពេញ, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩

លី តារាវុធ

# សេចក្តីផ្តើម

ខ្មែរកែច្នៃវត្ថុប្រើប្រាស់ប្រចាំថ្ងៃពីធនធានដែលមាននៅជុំវិញខ្លួន និងពីព្រៃនៅក្បែរៗស្រុកភូមិ មានដូចជាឈើ ឫស្សី វល្លិ ផ្តៅ ត្រឡោកដូង។ល។ អ្នកស្រែចម្ការចេះធ្វើវត្ថុទាំងនេះគ្រប់គ្នា។ សម្ភារៈច្នៃពីរុក្ខជាតិនេះ ខ្លះគេលាបជ័រម្រ័ក្សណ៍ប្រើសម្រាប់ដាក់ទឹកបានផង។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ គេផលិតរបស់របរប្រើប្រាស់ពីវត្ថុធាតុផ្សេងៗទៀតដែរ ដូចជាធ្វើពីដីដុត និងពីលោហធាតុជាដើម។ ចំពោះវត្ថុធ្វើពីដីដុត យើងឃើញមានតាំងពីរាប់ពាន់ឆ្នាំមកម៉្លេះ។ រហូតដល់នៅសម័យអង្គរ ការផលិតកុលាលភាជន៍មានទ្រង់ទ្រាយធំ ជាឧស្សាហកម្មដើម្បីបំពេញសេចក្តីត្រូវការទូទាំងប្រទេសទៀតផង។ ទន្ទឹមនឹងនេះ ខ្មែរក៏ផលិតវត្ថុប្រើប្រាស់ផ្សេងៗពីលោហធាតុដែរ ដូចជាស្ពាន់ ទង់ដែង សំរិទ្ធ ប្រាក់ ជួនកាលរហូតដល់មាសផង។ តឹកតាងដាក់ស្តែងជាបុរាណវត្ថុក៏ឃើញមាន រីឯការរៀបរាប់ក្នុងសិលាចារឹកវិញរឹតតែសម្បូណ៌ទៀត។

បើយោងតាមសិលាចារឹក យើងយល់ថាខ្មែរនិយមគ្រឿងប្រើប្រាស់ពីលោហធាតុណាស់។ គេយកលោហធាតុធ្វើជាវត្ថុប្រើប្រាស់សព្វសារពើ ដូចជាគ្រឿងប្រើប្រាស់សម្រាប់ចម្អិនអាហារ សម្រាប់ដាក់អាហារទទួលទាន គ្រឿងប្រើប្រាស់ក្នុងផ្ទះផ្សេងៗទៀតមានជើងពាន ថាស តុ ពែង ប៉ាន់ គ្រឿងហិបស្លារហូតដល់គ្រឿងបូជា មានបដិមា គ្រឿងតុបតែងលម្អ និងចុងក្រោយគឺគ្រឿងអលង្ការ។ ក្នុងចំណោមលោហធាតុដែលគេធ្វើជាគ្រឿងប្រើប្រាស់ដូចបានរៀបរាប់ខាងលើនេះ បើជាគ្រឿងចានក្បាន ហិបស្លា គ្រឿងតង្វាយ និងបដិមាវិញ គេធ្វើពីលោហធាតុមានតម្លៃដូចជាប្រាក់។ រីឯផ្ទះអភិជនខ្លះអាចមានធ្វើរហូតដល់មាសទៀតផង។ បើនៅក្នុងព្រះរាជវាំងវិញ ការប្រើប្រាស់វត្ថុធ្វើពីមាសគឺតែងមានជាធម្មតា។ វត្ថុដែលធ្វើពីមាសនិងប្រាក់ទាំងនោះមានរូបរាង ក្បូរក្បាច់និងមានសោភ័ណខ្លាំងណាស់។

ទោះបីតឹកតាងវត្ថុធ្វើពីប្រាក់ដែលមានចំណាស់ខ្លាំងឃើញមានដោយកម្រក្តី តែយើងយល់ថាគ្រឿងប្រាក់នៅសម័យបុរាណសម្បូណ៌ណាស់ ត្បិតអ្នកការទូត

ចិន ដែលមកដល់ប្រទេសកម្ពុជានៅរវាងដើមគ្រិស្តសករាជ បានអះអាងថាខ្មែរប្រើប្រាស់គ្រឿងប្រាក់ធ្វើជាចានក្បានសម្រាប់ទទួលទានបាយទៀតផង ដូចមាននៅក្នុងកំណត់ហេតុរបស់ *Kaing T'ai* និង *Chu Ying* សតវត្សទី៣ ដែលរៀបរាប់ដូច្នេះ៖

"...មាសនិងប្រាក់ គេប្រើធ្វើចានក្បាននិងគ្រឿងតុបតែង..."[១]

ការអះអាងរបៀបនេះមានជាហូរហែមករហូតដល់សម័យអង្គរ។ បើយើងយោងតាមកំណត់ហេតុរបស់លោកជីវ តាក្វាន់ ដែលមកស្នាក់នៅក្រុងអង្គរជិតមួយឆ្នាំ គឺនៅរវាងឆ្នាំ១២៩៦-៩៧។ លោកជីវ តាក្វាន់ រៀបរាប់ដូច្នេះថា៖

"...មនុស្សទាំងអស់នៅក្នុងគ្រួសារអភិជន ពេលពិសាបាយគេប្រើចានក្បានធ្វើពីប្រាក់ ជួនកាលរហូតដល់មាស។ នៅក្នុងឱកាសលៀងសាយភោជន៍ គេប្រើប្រាស់ចានក្បានធ្វើពីមាសយ៉ាងច្រើនសន្ធឹក ហើយមានក្បូរក្បាច់យ៉ាងពិចិត្រ..."[២]

បើពោលពីសិលាចារឹកវិញ យើងឃើញការលើកឡើងពីគ្រឿងប្រាក់តាំងពីដំបូងៗមកម្ល៉េះ។ មកដល់សម័យអង្គរ កាលណាគេរៀបរាប់ពីគ្រឿងប្រើប្រាស់និងតង្វាយទៅប្រាសាទ យើងតែងឃើញមានវត្ថុធ្វើពីប្រាក់ពុំដែលខាន។ ជួនកាលសិលាចារឹកទាំងនោះនិយាយថា គេយកគ្រឿងប្រាក់សម្រាប់ទូទាត់ទិញដូរដីស្រែ ឬខ្ញុំបម្រើ។ ផ្ទាំងចម្លាក់តាមប្រាសាទធំៗមួយចំនួនដូចជាអង្គរវត្ត បាយ័ន្ត និងបន្ទាយឆ្មារជាដើម យើងឃើញមានរូបជាច្រើនដែលបង្ហាញពីមនុស្សកាន់វត្ថុអ្វីម្យ៉ាងដែលមានក្បាច់យ៉ាងវិចិត្រនៅនឹងដៃ ដែលមើលទៅដូចគ្នានឹងជើងពានសព្វថ្ងៃ (រូបលេខ១)។ ដូច្នេះ បើផ្ទៀងផ្ទាត់វត្ថុទាំងនេះទៅនឹងកំណត់ហេតុលោក ជីវ តាក្វាន់ក្តី ទៅសិលាចារឹកក្តី ធ្វើឲ្យយើងជឿថាវត្ថុទាំងនេះគឺជាជើងពានប្រាក់ ឬមាសដែលមានក្នុងសេចក្តីរៀបរាប់នេះឯង។

---

១ *Brigg 1951: 14.*

២ *Zhou 1993: 59.*





រូបលេខ១៖ ជើងពាន (?) ឃើញមានតាមចម្លាក់នៅអង្គរវត្ត (សតវត្សទី១២)។

ជាទូទៅ ពត៌មានអំពីក្រោយសម័យអង្គរយើងដឹងតិចតួចតាមរយៈសិលាចារឹកខ្លះចារនៅសសរស្តម្ភនៃជាន់ព្រះពាន់ប្រាសាទអង្គរវត្ត និងព្រះរាជពង្សាវតារខ្លះដែលចារតៗគ្នា។ ជាទូទៅព្រះរាជពង្សាវតារនេះច្រើនតែចារឡើងវិញនៅរវាងសតវត្សទី១៩។ ដូច្នេះពត៌មានអំពីប្រាក់ក៏ដូច្នោះដែរ គឺយើងដឹងដោយប្រយោលប៉ុណ្ណោះ ក្នុងនោះពត៌មានខ្លះយើងដឹងតាមកំណត់ហេតុបរទេស។ រីឯសិលាចារឹកវិញយើងដឹងត្រឹមតែការប្រើប្រាស់ប្រាក់ជាគ្រឿងសម្រាប់ដោះដូរទំនិញ ទិញឬលោះខ្ញុំបម្រើប៉ុណ្ណោះ។ ក៏ប៉ុន្តែ យើងជឿថាគ្រឿងប្រាក់ គេនិយមហើយឲ្យតម្លៃខ្លាំងដូចនៅសម័យមុនៗដែរ ត្បិតបើពិនិត្យមើលតាមរឿងនិទាននិងសាស្ត្រាល្បែងនានា យើងតែងតែប្រទះឃើញគេលើកឡើងពីគ្រឿងប្រណីតៗជាពិសេសគ្រឿងប្រាក់ ដែលមានប្រើប្រាស់នៅក្នុងវាំងស្តេចនិងតាមគេហដ្ឋានអភិជនជាដើម។ រហូតមកដល់សតវត្សទី១៩ ជនជាតិអឺរុបដែលមកដល់ប្រទេសកម្ពុជានាពេលនោះ ក៏ឃើញថាគេនិយមគ្រឿងប្រាក់ដូច្នេះដែរ។ លោក Thomas Wallace Knox ដែលបានធ្វើដំណើរពាសពេញប្រទេសនៅអាស៊ីអាគ្នេយ៍ ហើយដែលបានទៅដល់ខេត្តសៀមរាបបានរៀបរាប់ថា៖

> "...លោកចៅហ្វាយខេត្ត (សៀមរាប) បានបង្ហាញគ្រឿងហិបស្លាម្លូនិងគ្រឿងផ្សេងៗទៀត។ គាត់ប្រាប់យើងថា គ្រឿងទាំងនេះធ្វើដោយជាងទងខ្មែរនៅខេត្តសៀមរាបដោយរំលាយកាក់មាសនិងប្រាក់សុទ្ធយកមកពីក្រុងវេ (អាណាម)..."[៣]

ដូច្នេះ យើងសង្កេតឃើញថាការផលិតគ្រឿងប្រាក់មានកំណើតរាប់ពាន់ឆ្នាំមកហើយ និងបន្តឥតដាច់។ សារជីវកម្មផលិតគ្រឿងប្រាក់ច្រើនតែប្រមូលផ្តុំនៅក្បែរក្រុង ឬនៅក្នុងក្រុង ហើយច្រើនមានទំនាក់ទំនងជាមួយព្រះរាជវាំងតែម្តង។ ជាអាទិ៍យើងឃើញភូមិមួយចំនួននៅក្បែរឧត្តុង្គ ដែលធ្លាប់ជារាជធានីចាស់

[៣] *Matic 2002,* Cambodian Silver Animals: A Long Tradition of Artistic Heritage, *Chulalongkorn University Press, p. 2-3.*



តាំងពីរវាងសតវត្សទី១៧ រហូតដល់ចុងសតវត្សទី១៩ អ្នកស្រុកបន្តរបរធ្វើប្រាក់ជាអាជីពរហូតដល់សព្វថ្ងៃ។ ពេលដែលរាជធានីលើកមកភ្នំពេញ ជាងចំណានៗដែលផលិតគ្រឿងប្រាក់ផ្គត់ផ្គង់ព្រះបរមរាជវាំងនិងរាជធានីក៏ផ្លាស់មកជាមួយហើយមកតាំងទីនៅម្តុំផ្សារស៊ីញ៉ែក តាមបណ្តោយវិថីព្រះសុធារសជាប់វត្តឧណ្ណាលោម ដែលនៅមិនឆ្ងាយពីព្រះរាជវាំង និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈសព្វថ្ងៃ។ ក្រោយមក ភូមិនេះក៏ក្លាយជាផ្សារលក់គ្រឿងប្រាក់យ៉ាងល្បីល្បាញនៅភ្នំពេញ ហើយដែលពីមុនមក ទេសចរស្គាល់ថាជាវិថីគ្រឿងប្រាក់។ នៅរវាងទសវត្ស១៩៥០ សកម្មភាពផលិតវត្ថុធ្វើពីប្រាក់កើនឡើងខ្លាំងណាស់ រហូតលេចចេញសិប្បកម្មខ្លះៗនៅទីក្រុងដើម្បីផ្គត់ផ្គង់ទីផ្សារសម្រាប់ប្រើក្នុងស្រុកផង និងសម្រាប់គោលដៅទេសចរបរទេសផង។ ពេលនោះម្ចាស់សិប្បកម្មធំៗនៅក្រុងភ្នំពេញមានបណ្តាញលក់នៅតាមប្រទេសធំៗមួយចំនួនទៀតដែរ។

ការកើនឡើងទីផ្សារគ្រឿងប្រាក់តែមួយរយៈខ្លីនោះក៏បាត់ទៅវិញ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចក្នុងចន្លោះឆ្នាំ១៩៧៥ដល់ដើមឆ្នាំ១៩៧៩។ ពេលនោះកម្មសិទ្ធិឯកជនត្រូវលុបបំបាត់។ វត្ថុធ្វើពីប្រាក់ដែលខ្មែររក្សាទុកតាមផ្ទះសម្រាប់ប្រើម្តងម្កាលក្នុងកិច្ចពិធី ត្រូវប្រមូលមកដាក់រួមក្នុងសហករណ៍ ត្បិតវត្ថុធ្វើពីប្រាក់ជានិមិត្តរូបនៃរបបសក្តិភូមិ ដែលជាសត្រូវនៃមនោគមវិជ្ជាវណ្ណៈអធនរបស់ពួកខ្មែរក្រហម។ របរធ្វើប្រាក់ក៏លែងមានតទៅទៀត។ គ្រឿងប្រាក់ខ្លះរស់រានមានជីវិតដោយសារជនភៀសខ្លួនខ្លះនាំទៅជាមួយនៅចន្លោះទសវត្ស១៩៧០[៤]។ ក្រោយរបបនេះដួលរលំនៅដើមឆ្នាំ១៩៧៩ ចលនាភៀសខ្លួនទៅប្រទេសលោកខាងលិចដោយឆ្លងកាត់ប្រទេសថៃឡង់ដ៍កើតឡើងយ៉ាងគគ្រឹកគគ្រេង។ ពេលនោះជនភៀសខ្លួននាំយកទៅជាមួយនូវអលង្ការមាស និងគ្រឿងប្រាក់ល្អៗដែលនៅសេសសល់ពីការបំផ្លាញរបស់ខ្មែរក្រហម សម្រាប់ធ្វើការដោះដូរស្បៀងអាហារឬជាលុយកាក់បានភ្លាមៗ។ មូលហេតុមួយទៀត ដែលនាំឲ្យវត្ថុធ្វើពីប្រាក់បាត់ស្ទើរអស់ពីស្រុកខ្មែរដែរ គឺដោយសារតែព្រឹត្តិការណ៍ខ្មែរក្រហម

[៤] *K.I. Matics, 2002, p. 1.*

ដែលកាត់ផ្តាច់ប្រទេសកម្ពុជាពីសហគមន៍អន្តរជាតិ ពេលនោះហើយដែលវត្ថុសិល្បៈខ្មែរក្លាយជាគោលដៅដែលគេធ្វើសមុច្ច័យវត្ថុសិល្បៈខ្មែរ ក្នុងចិត្តគំនិតមួយថា គេនឹងលែងមានទេសចរណ៍តទៅទៀត លាយឡំជាមួយសេចក្តីស្រណោះដល់ប្រទេសមួយដែលធ្លាប់មានអារ្យធម៌រុងរឿង។ ពេលនោះ ការរត់ពន្ធវត្ថុសិល្បៈខ្មែរទៅព្រំដែនក្លាយជាព្រឹត្តិការណ៍ធំមួយ ស្របពេលដែលតម្លៃប្រាក់នៅពិភពលោកឆ្នាំ១៩៨០-៨១ ឡើងខ្លាំងផង ឈ្មួញក្នុងស្រុកដើរប្រមូលទិញប្រាក់នាំទៅប្រទេសថៃឡង់ដ៍យ៉ាងសម្បើម។ មានតែវត្ថុណាដែលពិសេសខ្លាំងប៉ុណ្ណោះដែលគេទុកលក់ជាវត្ថុបុរាណ តែវត្ថុទូទៅយ៉ាងច្រើនគេរំលាយយកប្រាក់សុទ្ធដែលងាយលាក់កំបាំងពីភ្នែកសមត្ថកិច្ចផង និងងាយដឹកជញ្ជូនផង។ គ្រឿងប្រាក់ប្រណីតៗ កាក់ប្រាក់នៅសម័យឧត្តុង្គ និងកាក់ប្រាក់នៃសហព័ន្ធឥណ្ឌូចិន ក៏ដូចបដិមាចាស់ៗខ្លះនៅល្អ ខ្លះបាក់បែក ត្រូវគេរំលាយជាប្រាក់សុទ្ធដើម្បីលក់[៥]។ ចំនួនគ្រឿងប្រាក់នៅក្នុងស្រុកខ្មែរថយចុះយ៉ាងខ្លាំង ទន្ទឹមនឹងពេលដែលសិប្បកម្មធ្វើប្រាក់នៅបាងកកកើនឡើងក្រោយឆ្នាំ១៩៧៩[៦]។ ជាងប្រាក់ខ្មែរខ្លះដែលរត់ទៅជំរុំភៀសខ្លួនតាមបណ្តោយព្រំដែនខ្មែរ-ថៃ ក៏ទៅធ្វើការឲ្យរោងសិប្បកម្មប្រាក់នៅក្រុងបាងកក។

ក្រោយឆ្នាំ១៩៧៩ របរធ្វើប្រាក់នៅស្រុកខ្មែរពុំទាន់កើតឡើងវិញភ្លាមទេ។ បញ្ហាចោទគឺពុំមានប្រាក់សម្រាប់ការផលិត។ ពេលនោះប្រទេសខ្មែរពុំទាន់បើកទូលាយ និងស្ថិតនៅក្រោមការហ៊ុំព័ទ្ធសេដ្ឋកិច្ចនៅឡើយ។ សង្គ្រាមនៅបន្តតាមព្រំដែន។ រហូតមុនឆ្នាំ១៩៩០ ទេសចរមកកម្ពុជាក៏ពុំទាន់បើកទូលាយ។ គ្មានទីផ្សារ ការផលិតក៏នៅតែពុំទាន់មាន។ របរដែលគេខានធ្វើជាងបីឆ្នាំក្នុងសម័យខ្មែរក្រហម ក៏នៅតែមិនទាន់ដំណើរឡើងវិញភ្លាមៗបាន។ ជាងចាស់ៗខ្លះស៊ីឈ្នួលតាមផ្ទះឈ្មួញដែលដើរទិញប្រាក់មករំលាយ ដើម្បីលក់បន្ត ឬរត់ពន្ធ

៥ សេចក្តីពន្យល់របស់លោក ខេន និងលោកគ្រូ ជេត ចន ជាសាស្ត្រាចារ្យចូលនិវត្តន៍ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

៦ *K.I. Matics, p. 2.*



ទៅប្រទេសថៃឡង់ដ៍[៧]។ បន្តិចក្រោយមកទើបភូមិស្រុកដែលធ្លាប់ប្រកបរបរធ្វើប្រាក់ជាប្រពៃណីពីដូនតាមកនោះចាប់ផ្តើមឡើងវិញខ្លះ។ សាលារចនាបើកទ្វារទទួលសិស្សឲ្យចូលរៀន គ្រូចាស់ដែលសល់ពីស្លាប់ត្រឡប់មករកសាលាដែរ។ ការបង្រៀនផ្នែកចម្លាក់ប្រាក់ក៏ចាប់ផ្តើម។ បន្តិចម្តងៗ វិស័យនេះក៏ចាប់លូតលាស់ជាបណ្តើរៗ អ្នកភូមិនៅម្តុំកំពង់ហ្លួង កោះចិនក៏ចាប់អាជីពនេះឡើងវិញ។ តែភ្លាមៗនោះមិនដូចពីមុនទេ ការផលិតពេលនេះដើម្បីតែឈ្មួញនាំទៅប្រទេសថៃឡង់ដ៍ប៉ុណ្ណោះ។ ការប្រើប្រាស់ក្នុងស្រុកមិនដូចពីមុនទេ ត្បិតប្រទេសទើបរួចផុតពីសង្គ្រាម ហើយនៅក្រោមរបបកុម្មុយនីស្តនៅឡើយ។ រហូតដល់ជំនាន់អ៊ុនតាក់[៨] ទើបមានការផលិតពេញបន្ទុក ដោយសារពេលនោះតម្រូវការរបស់ទេសចរចាប់មានដំណើរឡើងវិញ តម្រូវការទីផ្សារនៅបាងកកក៏កើនឡើង។ ពេលនោះ ជាដំណាក់កាលបាត់បង់គ្រឿងប្រាក់ខ្មែរចាស់ៗជាចុងក្រោយ។ ការផលិតកើនឡើងយ៉ាងលឿនពេលនោះមិនទៀងទាត់ទេ ត្បិតតម្លៃគ្រឿងប្រាក់រត់តាមហាងឆេងប្រាក់នៅលើពិភពលោក។ បើតម្លៃប្រាក់ឡើងថ្លៃ គ្រឿងប្រាក់ក៏ត្រូវឡើងថ្លៃ។ ម្យ៉ាងវិញទៀតសកម្មភាពផលិតគ្រឿងប្រាក់សព្វថ្ងៃគឺដើម្បីបម្រើទីផ្សារទេសចរបរទេស រីឯទីផ្សារធំគឺនៅបាងកក។ ដូច្នេះ បើគ្រាន់តែសភាពការណ៍នៅព្រំដែនមិនស្រួល ការផលិតក៏ថយចុះ។ ជាងក៏លែងមានការងារធ្វើ។ ក្នុងរវាងប៉ុន្មានឆ្នាំនេះ តម្លៃប្រាក់នៅលើពិភពលោកឡើងយ៉ាងខ្ពស់និងបានប៉ះពាល់យ៉ាងខ្លាំងដល់របរផលិតគ្រឿងប្រាក់។ អ្នកខ្លះក៏បោះបង់របរនេះចោលទៅធ្វើស្រែចម្ការ ឬកម្មករនៅភ្នំពេញ។ ស្របពេលដែលមានការកើនឡើងរោងចក្រកាត់ដេរផង កូនចៅជាងទាំងនោះងាកមកធ្វើជាកម្មករនៅតាមការដ្ឋានសំណង់និងរោងចក្រនោះវិញ។ អ្នកបន្តចំណេះដឹងនេះពីឪពុកម្តាយក៏កាន់តែហោចទៅៗ។ វិស័យមួយដែលធ្លាប់ប្តុំប្តើងរុងរឿងខ្លាំង ទទួលការកោតសរសើរពីគេឯង និងអ្នកប្រមូលសមុច្ច័យវត្ថុសិល្បៈខ្មែរផងនោះ សព្វថ្ងៃកំពុងប្រឈមនឹងអនាគតមួយមិនច្បាស់លាស់។

៧ សេចក្តីពន្យល់របស់ជាងឡេង នៅភូមិពោធិតូច ឃុំកំពង់ហ្លួង ខេត្តកណ្តាល។

៨ *UNTAC (United Nation Transitional Authority in Cambodia).*

វត្ថុធ្វើពីប្រាក់ដែលយើងឃើញសព្វថ្ងៃ ជាគ្រឿងប្រើប្រាស់ដូចជាប្រអប់ម្លូស្លាកម្រមានអាយុលើសពី១០០ឆ្នាំណាស់ ភាគច្រើនធ្វើពីទសវត្ស១៩៣០ដល់១៩៥០។ ប៉ុន្តែប្រពៃណីនិងចំណេះក្នុងការផលិតវត្ថុពីប្រាក់ដែលមានយូរលង់មកហើយនោះ អ្នកស្រាវជ្រាវយល់ស្របគ្នាជាទូទៅថា បច្ចេកទេសផលិត និងប្រភេទគ្រឿងប្រាក់ហាក់មានការប្រែប្រួលតិចតួចប៉ុណ្ណោះរហូតដល់បច្ចុប្បន្ន។

ការសិក្សានេះ យើងនឹងពិនិត្យមើលតាមទីតាំងសំខាន់ៗបីកន្លែង។ ទីតាំងទីមួយ ការផលិតនៅតាមភូមិស្រុកដែលប្រកបរបរធ្វើប្រាក់តាំងពីដូនតាមកដល់បច្ចុប្បន្ន។ ភូមិទាំងនោះ យើងសង្កេតឃើញថាផ្តុំគ្នានៅក្បែរអតីតរាជធានីឧត្តុង្គ ពោលគឺតំបន់កំពង់ហ្លួង-កោះចិន។ កំពង់ហ្លួងនិងកោះចិនខ័ណ្ឌដាច់ពីគ្នាដោយទន្លេសាប តែយើងនឹងរាប់បញ្ចូលថាជាតំបន់តែមួយក្នុងការសិក្សានេះ។ ទីតាំងទីពីរ គឺជាងដែលកំពុងប្រកបរបរនៅភ្នំពេញ។ ជាងនៅភ្នំពេញភាគច្រើនជាជាងល្បីៗ និងធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលនៅសាលារចនា (សព្វថ្ងៃជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ) និងជាងចាស់ៗដែលធ្លាប់មានឈ្មោះកាលពីមុនសង្គ្រាម។ ទីតាំងទីបី យើងជ្រើសរើសយកខេត្តសៀមរាប ដោយសារនៅទីនោះ អ្វីៗមិនដូចជាងនៅភ្នំពេញនិងតំបន់កំពង់ហ្លួង-កោះចិនទេ។ ជាងខ្លះធ្វើចំណាកស្រុកពីកំពង់ហ្លួង-កោះចិនទៅកាន់ខេត្តសៀមរាបដើម្បីប្រកបរបរផ្ទាល់ខ្លួន ឬទៅស៊ីឈ្នួលម្ចាស់សារជីវកម្មគ្រឿងប្រាក់ ឬតាមហាងលក់វត្ថុអនុស្សាវរីយ៍។

ការកំណត់ន័យនៃជាងប្រាក់ក៏ជាបញ្ហាចោទមួយដែរក្នុងការសិក្សានេះ។ ពីមុនមកជាងមាសនិងជាងប្រាក់អាចរាប់បានថាជាមនុស្សតែមួយ។ ជាទូទៅជាងប្រភេទនេះគេច្រើនហៅថា“ជាងទង” ជាអ្នកធ្វើគ្រឿងមាសប្រាក់ជាដើម ហើយគ្រឿងដែលគេផលិតរាប់តាំងពីគ្រឿងអលង្ការហូតដល់វត្ថុធំៗសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃដូចជាផ្តិល ថាស ទៀប ឬព្រះបដិមាផ្សេងទៀតផង ជាពិសេសព្រះពុទ្ធរូប។ ជាងដែលធ្វើតែគ្រឿងអលង្ការមាស មិនរាប់ចូលក្នុងក្រុមជាងដែលយើងនឹងធ្វើការសិក្សានេះទេ។ យើងសិក្សាតែពីជាងប្រាក់ដែលធ្វើរបស់ទូទៅទាំងធំទាំងតូចពីប្រាក់ ស្ពាន់ ឬទង់ដែង។



## ការសិក្សាកន្លងមកអំពីគ្រឿងប្រាក់ខ្មែរ

គ្រឿងប្រាក់នៅស្រុកខ្មែររាប់បញ្ចូលថាជាគ្រឿងប្រណីតនៅអាស៊ីអាគ្នេយ៍។ គ្រឿងប្រាក់ទាំងនេះមានច្រើនប្រភេទ និងមានក្បូរក្បាច់ដែលអាចឲ្យគេដឹងពីទឹកដៃនិងកម្រិតសិល្បៈ។ ក៏ប៉ុន្តែមកដល់បច្ចុប្បន្ន អ្នកស្រាវជ្រាវជាទូទៅពុំសូវចាប់អារម្មណ៍លើវិស័យនេះប៉ុន្មានទេ ដោយសារមូលហេតុច្រើន។ មូលហេតុដែលគេដឹងគ្រប់គ្នានោះ គឺចង់ឬមិនចង់ សិល្បករនិងអ្នកស្រាវជ្រាវអំពីវិជ្ជាខ្មែរទាំងនោះច្រើនចាប់ចិត្តតែទៅលើភាពស្កឹមស្កៃ និងចំនួនដ៏ច្រើនលើសលុបនៃប្រាសាទបុរាណ បដិមា សិលាចារឹក និងបុរាណវត្ថុខ្លះ ដូចជាកុលាលភាជន៍ជាដើម។ បុរាណវត្ថុទាំងនោះទាក់ទាញការយកចិត្តទុកដាក់ ព្រមទាំងពេលវេលាអ្នកស្រាវជ្រាវអស់ជាងមួយសតវត្សមកហើយ។ ក្រោយមក ក្នុងរវាងទសវត្ស១៩៩០មកដល់បច្ចុប្បន្ន ការប្រទះឃើញឡដុតកុលាលភាជន៍សម័យអង្គរ និងការប្រទះឃើញស្ថានីយ៍បុរេប្រវត្តិថ្មីៗមួយចំនួន ធ្វើឲ្យអ្នកស្រាវជ្រាវនានារឹតតែជក់អារម្មណ៍ហើយមិនដកឃ្លាខ្លះពីទម្លាប់មុនៗនោះឡើយ។ កំណាយថ្មីៗទាំងនោះប្រទះឃើញអង្កាំ គ្រឿងមាស ប្រាក់ សំរិទ្ធ ដែក និងកុលាលភាជន៍ជាដើម។ ការរកឃើញថ្មីនេះ ស្របពេលដែលនិន្នាការសិក្សាពីបុរេប្រវត្តិនៅអាស៊ីអាគ្នេយ៍កំពុងពេញនិយមផង នាំឲ្យការសិក្សាអំពីគ្រឿងប្រាក់និងការផលិតនៅតែជារឿងបន្ទាប់បន្សំដដែល។ មានមូលហេតុផ្សេងទៀតដែលអាចបង្អាក់ការស្រាវជ្រាវលើវិស័យនេះ ក្នុងនោះមូលហេតុចម្បងមួយ គឺដោយសារតែវត្ថុធ្វើពីប្រាក់មានចំនួនតិច ហើយនៅរាយប៉ាយផង ខ្លះនៅតាមផ្ទះ ខ្លះនៅតាមហាងលក់បុរាណវត្ថុនៅបាងកក ហុងកុង។ល។ ខ្លះទៀតជាសមុច្ច័យឯកជននៅអឺរុប ឬសហរដ្ឋអាមេរិក។ មូលហេតុរួមផ្សំមួយទៀត គឺដោយសារគ្រឿងប្រាក់ដែលនៅមានហើយដែលអាចយកមកសិក្សាច្រើនតែជារបស់មិនសូវចាស់ផង ធ្វើឲ្យអ្នកស្រាវជ្រាវមិនសូវយកចិត្តទុកដាក់។ ក្នុងចំណោមគ្រឿងប្រាក់ទាំងនោះ មួយភាគ

---

៩ *Silice, André, "Exemple d'arts Cambodgien modern", Tome II, L'Orfèvrerie,* Arts et Archéologie Khmèrs, *1926, p. 241-52.*

តូចធ្វើនៅរវាងចុងសតវត្សទី១៩ ឬដើមសតវត្សទី២០ តែភាគច្រើនធ្វើនៅរវាងទសវត្ស១៩៥០។

ការសិក្សាដំបូងមួយអំពី "អលង្ការខ្មែរ" ដោយលោក André Silice ដែលចុះផ្សាយក្នុងកម្រងសិក្សាមួយរបស់លោក George Groslier ឈ្មោះ Arts et Archéologie Khmère ភាគទី២ នៅឆ្នាំ១៩២៦[៩]។ ក្រៅពីនោះ យើងមានទិន្នន័យប្រយោលខ្លះៗ ដែលអ្នកស្រាវជ្រាវខ្លះទៀតរៀបរាប់បន្តិចបន្តួចក្នុងការសិក្សាពីឧបករណ៍ខ្មែរផ្សេងទៀត ដូចជាសំរិទ្ធិ ឬកុលាលភាជន៍ជាដើម។ ក្រៅពីនេះ មានការលើកយកមកនិយាយខ្លះក្នុងការសិក្សាអំពីអលង្ការនៅអាស៊ីអាគ្នេយ៍ទាំងមូល[១០]។ រហូតដល់មុនឆ្នាំ១៩៧១ គេពុំឃើញមានការសិក្សាដោយឡែកតែអំពីប្រាក់មួយមុខទេ។ នៅឆ្នាំ១៩៧១ អ្នកស្រី ប៉ាញ់ ម៉ីហឿង បានសិក្សាអំពីគ្រឿងប្រាក់ខ្មែរ ធ្វើក្នុងក្របខ័ណ្ឌសារណាថ្នាក់បរិញ្ញាប័ត្រនៃមហាវិទ្យាល័យបុរាណវិទ្យានាពេលនោះ។ ជាអកុសល សារណាដែលបោះពុម្ពជារ៉ូណេអូនេះមានតែ៥ក្បាល ហើយប្រហែលជាគេពុំអាចរកបានទៀតផង។ រីឯឯកសារសម្រាប់ការបង្រៀននៅមហាវិទ្យាល័យសូនរូប មួយភាគធំត្រូវបាត់បង់នៅសម័យខ្មែរក្រហម។ ឯកសារស្រាវជ្រាវខ្លះៗដែលនៅសេសសល់ គេរក្សាទុកនៅផ្ទះរៀងៗខ្លួន ដោយមិនបញ្ចេញជាសាធារណៈផង។ នេះជាបញ្ហាទម្លាប់របស់ជាងនិងសិល្បករខ្មែរជាទូទៅ ដែលក្លាយជាទម្លាប់ដល់បច្ចុប្បន្ន។ កាលណាមនុស្សស្លាប់ វិជ្ជាក៏ស្លាប់ទៅតាម។ រហូតមកដល់ឆ្នាំ២០០២ ទើបគេឃើញមានការស្រាវជ្រាវហ្មត់ចត់ថ្មីមួយអំពីគ្រឿងប្រាក់ខ្មែរ តែក៏ផ្តោតត្រឹមតែគ្រឿងប្រាក់រូបសត្វប៉ុណ្ណោះ។ ការសិក្សានេះធ្វើឡើងដោយអ្នកស្រី K. I. Matics[១១] ក្រោមចំណងជើងថា "Cambodian Silver Animals" (ប្រអប់រូបសត្វអំពីប្រាក់នៅស្រុកខ្មែរ) ហើយផ្សព្វផ្សាយដោយសាកលវិទ្យាល័យ Chulalongkorn ប្រទេសថៃឡង់ដ៍។

---

[១០] *Richter, Anne, 2000,* The Jewelry of Southeast Asia, *Thames & Hudson, London.*

[១១] *K.I. Matics, 2002.*

# ប្រាក់និងសង្គមខ្មែរ



Les projets matrimoniaux mûrissent lentement au Cambodge : Les envoyés du prétendant, les « moha » formulent la demande en mariage aux « méba » représentant les parents de la Jeune fille.

សម័យបុរាណ គ្រួសារខ្មែរដែលមានជីវភាពធូរធារប្រើប្រាស់គ្រឿងប្រាក់ក្នុងជីវភាពប្រចាំថ្ងៃ និងកិច្ចពិធីផ្សេងៗ។ ឯក្នុងព្រះរាជវាំង ការប្រើគ្រឿងប្រាក់ជារឿងធម្មតា ជួនកាលរហូតដល់មាសទៀតផង។ សព្វថ្ងៃ វត្ថុទាំងនោះមានដាក់តាំងនៅហោសិរីទ្ធិភិមាននិងព្រះវិហារព្រះកែវមរកតនៃព្រះបរមរាជវាំង។ ការប្រើប្រាស់គ្រឿងប្រាក់បញ្ជាក់ពីកម្រិតវប្បធម៌ និងកម្រិតជីវភាពនៃអ្នកប្រើផង។

ការប្រើប្រាស់គ្រឿងប្រាក់នៅសម័យបុរាណ គេដឹងតាមប្រភព៣សំខាន់ៗ គឺទី១ ប្រភពឯកសារនៃបេសកជនទូតបរទេស ជាពិសេសអ្នកការទូតចិន។ ទី២ សិលាចារឹក និងទី៣ បុរាណវត្ថុដែលមាននៅសេសសល់ដល់សព្វថ្ងៃ ខ្លះមាននៅតាមផ្ទះ ខ្លះរក្សាទុកនៅតាមសារមន្ទីរមួយចំនួន និងខ្លះទៀតប្រទះឃើញតាមរយៈកំណាយផ្សេងៗ។ ការសិក្សាពីជាតិពន្ធុសាស្ត្រពីរបៀបរស់នៅនិងវត្ថុដែលប្រើប្រាស់សព្វថ្ងៃក៏អាចផ្តល់ពន្លឺខ្លះពីគ្រឿងប្រាក់និងការប្រើប្រាស់នៅសម័យបុរាណដែរ។ រីឯអ្វីៗដែលយើងដឹងតាមសិលាចារឹកនិងបុរាណវត្ថុក៏ជួយឲ្យយើងយល់បានពីគ្រឿងប្រាក់ដែលមានក្នុងពេលបច្ចុប្បន្នបាន។

យើងដឹងថាចាប់ពីរវាងពាក់កណ្តាលសតវត្សទី១៥ ខ្មែរប្តូររាជធានីពីអង្គរដោយសារការលុកលុយនៃអាណាចក្រសៀមដែលកាន់តែខ្លាំងទៅៗ។ ចម្បាំងរាំងជល់ជាមួយប្រទេសជិតខាងចេះតែបន្ត ហើយចាប់ពីពេលនោះមក ខ្មែរច្រើនតែចាញ់ ធ្វើឲ្យទឹកដីកាន់តែរួញទៅៗ។ ពេលដែលសត្រូវលុកលុយម្តងៗ ជាពិសេសសៀម គេតែងយកវត្ថុប្រណីតៗជាគ្រឿងមាសប្រាក់និងកេណ្ឌប្រជាជន ក្នុងនោះរួមទាំងជាង និងសិល្បករល្បីៗទៅប្រទេសគេវិញ។ ដូច្នេះជារឿងធម្មតា កាលណាយើងឃើញគ្រឿងប្រាក់ខ្មែរនៅប្រទេសសៀម។ វត្ថុទាំងនេះមានរូបរាងដូចគ្នាក្បូរក្បាច់ស្រដៀងគ្នាច្រើន និងមានឈ្មោះដូចគ្នាទៀតផង។ ទន្ទឹមនឹងនេះទំនៀមនៃការប្រើប្រាស់គ្រឿងប្រាក់ក្នុងជីវិតប្រចាំថ្ងៃ និងក្នុងកិច្ចបូជានិងបុណ្យទានផ្សេងៗរវាងប្រទេសខ្មែរនិងសៀមក៏មានចំណុចដូចគ្នាច្រើនអន្លើ។

យើងបាននិយាយក្នុងសេចក្តីផ្តើមខ្លះៗមកហើយថា ខ្មែរផលិតសម្ភារៈប្រើប្រាស់ពីវត្ថុធាតុផ្សេងៗ មានឈើលាបម្រ័ក្សណ៍ ឫស្សី ផ្តៅ រពាក់ និងត្រឡោកដូងជាដើម។ បន្ទាប់មក យើងអាចឃើញមានភាជន៍ធ្វើពីដីដុត ក្នុងនោះមាន



តាំងពីចានក្បានសម្រាប់ទទួលទានអាហារ រហូតដល់វត្ថុធំៗសម្រាប់ដាក់គ្រឿងប្រៃ ជូរ និងវត្ថុរាវៗ។ ក្នុងការផលិតកុលាលភាជន៍តម្រូវឲ្យមានជំនាញ និងប្រភពរូបធាតុដើមនៅក្បែរនេះ ហើយការផលិតសោតគឺក្នុងទ្រង់ទ្រាយជាឧស្សាហកម្មផង។ រីឯការងារជាងខ្លះទៀត តែងភ្ជាប់ទៅនឹងជីវភាពអ្នកទីក្រុងឬអភិជន។ នៅក្បែររាជធានី ឬក្នុងរាជធានីតែម្តង គេតែងឃើញមានក្រុមជាងពិសេសដែលធ្វើអលង្ការនិងរបស់ប្រើប្រាស់ពីលោហធាតុផ្សេងៗ មានមាស ប្រាក់ ស្ពាន់ សំរិទ្ធិជាដើម។ ក្នុងឱកាសមុខមាត់ ដូចជាក្នុងមង្គលការឬទទួលភ្ញៀវពន្ទី គេតែងបញ្ចេញគ្រឿងប្រាក់ទាំងនេះមកប្រើប្រាស់ ក្នុងនោះយើងឧស្សាហ៍ឃើញមានផ្តិលប្រាក់ ជើងពាន ជើងស្រាពក៏ និងគ្រឿងប្រអប់ម្លូស្លាជាដើម។ វត្ថុទាំងនេះ គេរក្សាជាកេរ្តិ៍មរតក ហើយគេប្រើតៗគ្នាច្រើនជំនាន់ទៀតផង។ អ្នកដែលទទួលទានម្លូស្លាតែងមានហិបស្លា ដែលក្នុងនោះមានគ្រឿងផ្សេងៗ ដូចជាប្រអប់ស្លា ម្លូ អកកំបោរ និងសិងធ្វើពីស្ពាន់ ឬប្រាក់។ សព្វថ្ងៃវត្ថុទាំងនេះ ភាគច្រើនឃើញនៅតាមតូបក្នុងផ្សារថ្មី ផ្សារទួលទំពូង ឬហាងលក់វត្ថុសិល្បៈនៅភ្នំពេញនិងសៀមរាប។

បើពិនិត្យមើលតាមទិន្នន័យចាស់ៗជារូបចម្លាក់តាមប្រាសាទក្តី សិលាចារឹកក្តី រឿងព្រេងនិទានក្តី យើងសង្កេតឃើញថាខ្មែរនិយមនិងឲ្យតម្លៃគ្រឿងប្រើប្រាស់ពីលោហធាតុ។ ក្នុងរឿងព្រះគោព្រះកែវ ព្រះគោបានក្អួតម្ហូបអាហារមកឲ្យព្រះកែវជាប្អូនទទួលទាន ដោយមានចានក្បានធ្វើពីមាសនិងប្រាក់ដែលជាមូលហេតុនាំឲ្យអ្នកស្រុកតាមចាប់ព្រះគោដើម្បីយកគ្រឿងទាំងនោះ។ ជារឿយៗយើងតែងឮអ្នកស្រុកដែលរស់នៅក្បែរបុរាណដ្ឋានណាមួយដំណាលថា ពីជំនាន់មុនពេលមនុស្សស្មោះត្រង់និងមានធម៌ កាលណាគេរៀបធ្វើបុណ្យទានធំៗ គេតែងទៅបួងសួងសុំខ្ចីចានក្បានធ្វើពីមាស ប្រាក់ជាដើម ពីប្រាសាទបុរាណ ពីរូងភ្នំសក្តិសិទ្ធិ។ ជំនឿនេះឃើញថាមិនមានអ្វីខុសទេ ត្បិតបើយើងមើលតាមសិលាចារឹកយើងដឹងថាគ្រឿងតង្វាយ និងគ្រឿងប្រើប្រាស់តាមប្រាសាទនាសម័យនោះសុទ្ធតែជាវត្ថុប្រណីត ក្នុងនោះមានមាសនិងប្រាក់ជាច្រើនផង។ ដូច្នេះការជឿបែបនេះបង្ហាញពីសេចក្តីចងចាំលាយឡំការសោកស្តាយសម័យកាលមួយដែលធ្លាប់ថ្កុំថ្កើងផង និងបង្ហាញពីអ្វីដែលគេនៅចងចាំនៅឡើយថា នៅតាមប្រាសាទទាំង

នោះមានគ្រឿងមាសប្រាក់។ សព្វថ្ងៃនៅតាមស្រុកស្រែ ពេលមានបុណ្យទានម្តងៗ អ្នកស្រុកតែងតែខ្ចីចានក្បានពីវត្ត ដូចជាទំនៀមពីបុរាណមកនោះដែរ។

ចំណុចមួយទៀតដែលយើងគួរកត់សម្គាល់ជាពិសេសដែរ គឺរបៀបប្រើប្រាស់គ្រឿងប្រាក់ក្នុងសង្គមខ្មែរ។ យើងសង្កេតឃើញច្បាស់ថា គេចាត់ទុកគ្រឿងប្រាក់មានតម្លៃលើសពីអ្វីដែលជាវត្ថុសម្រាប់ប្រើប្រាស់ទៅទៀត ពោលគឺគេទុកជាទ្រព្យសម្បត្តិនៃគ្រួសារនីមួយៗតែម្តង ត្បិតវត្ថុខ្លះគេស្ទើរតែមិនហ៊ានយកមកប្រើផង ឬក៏ប្រើម្តងម្កាលប៉ុណ្ណោះ។

ជាបន្ត យើងនឹងលើកយកចំណុចនីមួយៗមកពិនិត្យដោយឡែកៗពីគ្នាៈ ១- គ្រឿងប្រាក់និងការប្រើប្រាស់។ ២- ប្រាក់និងជំនឿ។ ៣- ប្រាក់និងទ្រព្យសម្បត្តិនៃគ្រួសារខ្មែរ។ ៤- ប្រាក់កាក់។ ៥- អំពីប្រាក់និងព្រះមហាក្សត្រ។

## ១. គ្រឿងប្រាក់និងការប្រើប្រាស់

នៅកម្ពុជា យើងសង្កេតឃើញថាគេប្រើប្រាស់ប្រាក់សម្រាប់តែផលិតគ្រឿងប្រើប្រាស់រាល់ថ្ងៃ ជាគ្រឿងតុបតែង ជាគ្រឿងបូជា និងជារូបិយវត្ថុ។ គ្រឿងប្រាក់ទាំងនេះ ខ្លះបាត់បង់ ហើយដែលគេស្គាល់ត្រឹមតែឈ្មោះឬលែងស្គាល់តែម្តង។ ទន្ទឹមនឹងនេះ គ្រឿងប្រាក់ខ្លះលេចឡើងថ្មី ជាពិសេសចាប់ពីជំនាន់អាណាព្យាបាលបារាំង។ បើពោលសង្ខេប យើងអាចចែកជា៥ប្រភេទធំៗ គឺ ១- គ្រឿងអលង្ការ ២- គ្រឿងតុបតែងលម្អ ៣- គ្រឿងប្រើប្រាស់តាមផ្ទះ ៤- គ្រឿងប្រើក្នុងកិច្ចពិធីនិងបដិមា និង ៥- កាក់ជារូបិយវត្ថុប្រើសម្រាប់ចាយវាយដោះដូរទំនិញ។

### អលង្ការ

ប្រាក់មានតម្លៃបន្ទាប់ពីមាស ដោយសារប្រាក់មិនរងប៉ះពាល់នឹងអាស៊ីតក្នុងបរិយាកាស និងទន់ស្វិត ដែលគេអាចពត់ឬដំបានតាមចិត្តចង់។ មនុស្សចេះយកប្រាក់ធ្វើជាអលង្ការ និងដើម្បីតុបតែងលម្អរាប់ពាន់ឆ្នាំមកហើយ។ នៅកម្ពុជា យើងប្រទះឃើញគ្រឿងអលង្ការប្រាក់យ៉ាងហោចណាស់ប្រមាណ៥០០ឆ្នាំមុន គ.ស.មកម្ល៉េះ។ កំណាយនៅស្ថានីយ៍បុរេប្រវត្តិ និងក្រោយបុរេប្រវត្តិសាស្ត្រមួយ





រូបលេខ២៖ អលង្ការមាសនិងប្រាក់ដែលគេប្រទះឃើញក្នុងកំណាយនៅស្ថានីយ៍ព្រហារ ខេត្តព្រៃវែង (រូបថតដោយ *Andrea Reinecke*)។

ចំនួន គេប្រទះឃើញគ្រឿងអលង្ការមាសនិងប្រាក់នៅជាមួយគ្នា។ កំណត់ហេតុនៃបេសកជនការទូតចិនខាងលើនាំឲ្យគេដឹងថាមានអលង្ការជាច្រើនធ្វើពីមាសនិងប្រាក់។ បន្ទាប់មក យើងមានទិន្នន័យពីអលង្ការនៅសម័យបុរាណតាមរយៈសិលាចារឹក និងផ្ទាំងចម្លាក់តាមជញ្ជាំងប្រាសាទ។

ស្ថានីយ៍បុរេប្រវត្តិដែលគេប្រទះឃើញនៅខេត្តព្រៃវែង និងនៅខេត្តបន្ទាយមានជ័យ គេរកឃើញអលង្ការធ្វើពីមាស ប្រាក់ សំរឹទ្ធិ ដែក ឬអង្កាំ នៅលាយឡំជាមួយឧបករណ៍ផ្សេងៗ ដែលគេដាក់ជាមួយសព។ ស្ថានីយ៍បិទមាសនិងព្រហារ (ឃុំជ្រៃ ស្រុកព្រៃវែង ខេត្តព្រៃវែង) ដែលគេទើបដឹងថ្មីៗនៅដើមឆ្នាំ២០០៧ គេរកឃើញគ្រឿងអលង្ការមាស ប្រាក់ សំរឹទ្ធិ ដែក និងអង្កាំនៅលាយឡំគ្នា។ អលង្ការធ្វើពីមាសនិងប្រាក់ដែលគេប្រមូលពីកំណាយនេះ មានចំនួនសរុបប្រមាណ៩០មុខ ក្នុងនោះមានក្រវិល ចិញ្ចៀន ឬកងដៃ (រូបលេខ២)។ ក្នុង

ចំណោមអលង្ការមាស គេវិភាគឃើញថាមានបរិមាណជាតិប្រាក់ច្រើនលើសលុបផង។ ស្ថានីយ៍ទាំងពីរពោលខាងលើនេះ មានអាយុកាលប្រមាណ២០០ឆ្នាំទៅ៥០០ឆ្នាំចាស់ជាងហ្វូណន[៣៥]។ លោក *Andreas Reineke* និង វិន ឡៃជូ ដែលបានដឹកនាំការស្រាវជ្រាវនេះចាប់អារម្មណ៍ថា មានចំណុចគួរឲ្យកត់សម្គាល់មួយទាក់ទងនឹងរបៀបដែលគេដាក់អលង្ការទាំងនេះថា សពដែលមានពាក់អលង្ការមាស គេច្រើនឃើញអលង្ការប្រាក់នៅជាគូនឹងគ្នា ពោលគឺគេពាក់អលង្ការមាសខាងស្ដាំ ឯប្រាក់គេពាក់ខាងឆ្វេង។ រីឯសពដែលមានអលង្ការសំរឹទ្ធិច្រើនតែឃើញមានអលង្ការដែកជាគូដូចគ្នា ពោលគឺសំរឹទ្ធិខាងស្ដាំ ដែកខាងឆ្វេង។ ដូច្នេះការប្រើប្រាស់លោហធាតុនេះទៀតសោត ប្រហែលជាមានទាក់ទងនឹងជំនឿផង។ នៅស្ថានីយ៍ភូមិស្នាយនិងស្ថានីយ៍ឃើញថ្មីៗនៅបន្ទាយមានជ័យ គេក៏ប្រទះឃើញអលង្ការមាសនិងប្រាក់កប់ជាមួយសពដូចគ្នាដែរ។ ក្រុមបុរាណវិទូជប៉ុនដែលធ្វើការស្រាវជ្រាវនៅភូមិស្នាយនេះ បានធ្វើវិភាគលើក្រវិលមួយគូធ្វើពីមាសហើយផ្ដល់លទ្ធផលថាមានជាតិមាស៧០ភាគរយ និងប្រាក់៣០ភាគរយ។ លទ្ធផលនេះនាំឲ្យគេសន្និដ្ឋានថា មនុស្សជំនាន់នោះមានគំនិតលាយប្រាក់បញ្ចូលមាស ដើម្បីធ្វើឲ្យអលង្ការមានភាពរឹងមាំល្អ[៣៦]។ ភស្តុតាងនេះបញ្ជាក់ថាជំនាន់នោះ គេមិនត្រឹមតែស្គាល់ប្រាក់ប៉ុណ្ណោះទេ ថែមទាំងដឹងពីរបៀបលាយជាមួយមាសក្នុងគោលបំណងពង្រឹងគ្រឿងអលង្ការឲ្យរឹងមាំល្អទៀតផង។ អ្វីដែលគេប្រទះឃើញនៅភូមិស្នាយហាក់បង្ហាញថា សពទាំងនោះប្រហែលជាក្រុមមនុស្សដែលមានយសសក្តិខ្ពង់ខ្ពស់ និងមានទ្រព្យសម្បត្តិទៀតផង។

មកដល់សម័យចន្លោះបុរេប្រវត្តិនិងប្រវត្តិសាស្ត្រ ព្រមទាំងដំណាក់កាលដំបូងៗនៃប្រវត្តិសាស្ត្រគឺតឹកតាងជាអលង្ការធ្វើពីមាសនិងប្រាក់មានច្រើនគួរសមដែរ។ កំណាយនៅអូកែវ ដែលដឹកនាំដោយលោក *Louis Malleret* នៅឆ្នាំ១៩៤៧

[៣៥] *Reinecke et all, pp. 40-41*

[៣៦] របាយការណ៍កំណាយស្រាវជ្រាវស្ថានីយ៍បុរាណនៅភូមិស្នាយ ឆ្នាំ២០០៧ រៀបរៀងដោយ *Yoshinori Yasuda* និង ជុច គឿន មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការស្រាវជ្រាវវប្បធម៌ជប៉ុន ទំ. ១៤១-១៤២។



គេប្រទះឃើញអលង្ការចំនួន១៣២០ ដែលក្នុងនោះអលង្ការមាសមានទម្ងន់សរុប ១១៣១ក្រាម ហើយវត្ថុផ្សេងទៀតជាប្រាក់ ត្បូង អង្កាំ និងកម្ទេចកម្ទីមាសប្រាក់ ដែលជ្រុះនៅតាមផ្ទះឬរោងជាងទង ក៏ដូចជាឧបករណ៍ជាងទងមួយចំនួន[៣៧]។ តឹកតាងនៃកម្ទេចកម្ទីមាសនៃរោងជាងនេះសំខាន់ណាស់ បង្ហាញថាការធ្វើអលង្ការនាពេលនោះមមាញឹកខ្លាំង។

ក្នុងសម័យហ្វូណនដដែលនេះ យើងឃើញមានកំណត់ហេតុព្រះសង្ឃព្រះនាមនាគសេននៃសន្តិវង្ស *C'hi* ខាងជើង (គ.ស.៤៧៩-៥០១) រៀបរាប់ថា៖

> ...ក្នុងចំណោមទំនិញផ្សេងៗ គេឃើញមានមាស ប្រាក់ សូត្រ។
> ...ប្រជាជននៃហ្វូណនធ្វើចិញ្ចៀននិងកងដៃពីមាស និងចានក្បានពីប្រាក់...[៣៨]

កំណត់ហេតុនៃបេសកជនការទូតចិនខាងលើនាំឲ្យគេដឹងថាមានអលង្ការជាច្រើនធ្វើពីមាសនិងប្រាក់។ បន្ទាប់មក យើងមានទិន្នន័យពីអលង្ការនៅសម័យបុរាណតាមរយៈសិលាចារឹក និងផ្ទាំងចម្លាក់តាមជញ្ជាំងប្រាសាទនានា។ សិលាចារឹកសម័យមុនអង្គរ និងសម័យអង្គររៀបរាប់យ៉ាងច្រើនពីអលង្ការ និងគ្រឿងតុបតែងលម្អធ្វើពីមាសនិងប្រាក់ ដែលទាយកទាយិកាធ្វើជាតង្វាយដល់ទេព ឬបុគ្គលដែលគេតម្កើងស្មើទេពក្រោយពេលស្លាប់ទៅ។ សិលាចារឹកនៃប្រាសាទព្រះឥន្ទ្រកោសីយ៍ (*K. 262, 263*) មាននិយាយយ៉ាងច្រើន អំពីតង្វាយជាអលង្ការនិងគ្រឿងតុបតែងលម្អដល់បដិមាទេព និងមនុស្សដែលគេលើកតម្កើងជាទេពនៅក្នុងប្រាសាទនេះ។ គ្រឿងទាំងនោះបើយើងយកតែគ្រឿងអលង្ការនិងគ្រឿងតុបតែងមកពិនិត្យឃើញថាច្រើនគួរសម មានដូចជាចិញ្ចៀន ក្រវិល កងដៃ ស្នាប់ដៃម្ជុជ និងគ្រឿងលម្អស្រោបនិងពាសពីលើដងខ្លួនបដិមា[៣៩]។ល។ ផ្ទាំងចម្លាក់នៅ

[៣៧] *Malleret, Louis, 1962,* L'Archéologie du Delta du Mékong, *tome III, p. 37.*

[៣៨] *Brigg 1951: p. 29.*

[៣៩] ទាក់ទងនឹងគ្រឿងអលង្ការសម័យចាស់ សូមមើលសៀវភៅ *Adoration and Glory* របស់អ្នកនិពន្ធ *Emma C. Bunker* និង *Latford Douglas*។

ប្រាសាទធំៗមួយចំនួន ដូចជាអង្គរវត្ត បាយ័ន្ត បន្ទាយឆ្មារៗល។ យើងឃើញថា ជាទូទៅ តួអង្គនីមួយៗតែងមានតុបតែងខ្លួនដោយ គ្រឿងអលង្ការយ៉ាងស្កុកស្កម្ភរហូតដល់រូប កូនក្មេងទៀតផង (រូបលេខ២៣)។ ឧទាហរណ៍ របៀបនេះឃើញថាមានច្រើនណាស់ មិន ចាំបាច់នឹងលើកមកនិយាយវែងឆ្ងាយទេ។ សព្វថ្ងៃ ទោះបីមនុស្សនិយមអលង្ការមាស ជាងក្តី ក៏យើងនៅឃើញមានអ្នកខ្លះធ្វើពី ប្រាក់ដែរ ជាពិសេសគេនិយមធ្វើជាកងដៃ (រូបលេខ២៤) ខ្សែក។



រូបលេខ២៣៖ កុមារពាក់គ្រឿងអលង្ការ (ចម្លាក់នៅអង្គរវត្ត)។



រូបលេខ២៤៖ កងដៃបច្ចុប្បន្នធ្វើពីប្រាក់ (សមុច្ច័យឯកជន)។

## គ្រឿងប្រើប្រាស់

គ្រឿងប្រើប្រាស់តាមផ្ទះ យើងរាប់តាំងពីគ្រឿងចានក្បានរហូតដល់គ្រឿងផ្ទុកវត្ថុអ្វីមួយ ដូចជាគ្រឿងស្លាម្ល ក្រមួន ប្រេង ម្សៅជាដើម។ ប៉ុន្មានទសវត្សមុននេះ នៅតាមផ្ទះអភិជននិងអ្នកដែលមានជីវភាពធូរធារតែងមានគ្រឿងប្រាក់ ដូចជាចាន ស្លាបព្រា វែក ចង្កឹះ ផ្តិល ប៉ាន់តែ ពែង ពាន ថាស រហូតដល់កន្ថោរស្តោះទឹកមាត់ស្លា។ បើនៅក្នុងវាំង ការប្រើប្រាស់គ្រឿងប្រាក់គឺជារឿងធម្មតា។ ការប្រើប្រាស់វត្ថុទាំងនេះដើម្បីបង្ហាញពីយសសក្តិមុខមាត់ផង។ ក្នុងរូបលេខ២៥ និងរូបលេខ២៦ ជាមន្ត្រីជាន់ខ្ពស់ខ្មែរនាដើមសតវត្សទី២០ ដែលនៅក្បែរនោះ គេឃើញមានគ្រឿងប្រាក់រចនាយ៉ាងពិចិត្រ។

ជាទូទៅ គេទុកដាក់គ្រឿងប្រណីតៗដែលមានតម្លៃដូចជាគ្រឿងប្រាក់នៅកន្លែងទីទៃពីចានក្បានដែលធ្វើពីដីដុត ឬលោហធាតុមិនសូវមានតម្លៃផ្សេងទៀត។ ចាន ស្លាបព្រា... ដែលធ្វើពីដីដុតឬលោហធាតុធម្មតា គេទុកក្នុងរាវដែលតែងតែនៅចង្ក្រានបាយ រីឯគ្រឿងប្រាក់ គេរក្សាក្នុងទូកញ្ចក់ត្រឹមត្រូវ ហើយច្រើនតែឃើញនៅល្វែងធំ ជាកន្លែងទទួលភ្ញៀវ ដែលគេហៅជាទូទៅថា "ទូតាំង" ដូច្នេះតែម្តង ត្បិតគេប្រើសម្រាប់រក្សាទុកផង តាំងបង្ហាញផង (រូបលេខ២៧)។ របស់ទាំងនេះគេបញ្ចេញមកប្រើប្រាស់ម្តងម្កាលពេលមានភ្ញៀវពន្ទឺឬបុណ្យទានប៉ុណ្ណោះ។



រូបលេខ២៥៖ គ្រឿងប្រាក់ដែលមាននៅតាមផ្ទះអភិជននៅដើមសតវត្សទី២០ (រូបថត៖ រោងជាងជួសជុលចម្លាក់ថ្មនៃសារមន្ទីរជាតិភ្នំពេញ)។



រូបលេខ២៦៖ គ្រឿងប្រាក់ដែលមាននៅតាមផ្ទះអភិជននៅដើមសតវត្សទី២០ (រូបថត៖ *Paul Collard 1925, Cambodge et Cambodgiens, Societé d'Edition Géographiques, Maritimes et Coloniales, Pairs*)។



រូបលេខ២៧៖ គ្រឿងប្រាក់ដែលគេរក្សានៅតាមផ្ទះ (សមុច្ច័យឯកជន)។

យើងអាចបែងចែកគ្រឿងទាំងនេះជាពីរប្រភេទធំៗជាបន្តទៀត៖ ប្រភេទទី១ ជាគ្រឿងប្រាក់បែបប្រពៃណី ដែលគេមានតាំងពីបុរាណតរៀងមក មានដូចជាផ្តិល ខាល ទៀប ពាន តុ ថាស គ្រឿងហិបស្លា។ល។ ប្រភេទទី២ ជាគ្រឿងប្រាក់ដែលគេច្នៃថ្មីតាមលំនាំវត្ថុមានប្រើនៅអឺរុប ឬច្នៃបង្កើតថ្មីទៅតាមសម័យកាល មានដូចជាសម ស្លាបព្រា វែក ប្រអប់បារីស៊ីហ្គារ ស្រោមដែកកេស ធុងទឹកកក។ល។ វត្ថុទាំងនេះ គេធ្វើឡើងក្រោយសម័យបារាំង ហើយសម្រាប់បំពេញតម្រូវការរបស់បារាំងនិងអភិជនខ្មែរនាពេលនោះ។



## គ្រឿងប្រាក់ខ្មែរ

គ្រឿងប្រាក់បែបប្រពៃណី គឺសំដៅប្រភេទគ្រឿងប្រាក់ដែលគេផលិតតាំងពីបុរាណតរៀងមកដល់បច្ចុប្បន្ន ហើយដែលនៅរក្សាតាមលំនាំរូបរាងនិងក្បូរក្បាច់ដូចពីបុរាណ។ យើងស្នើពាក្យថា “គ្រឿងប្រាក់ខ្មែរ” មកសម្គាល់គ្រឿងទាំងនេះ។ គ្រឿងប្រាក់ខ្មែរអាចបែងចែកជាប្រភេទផ្សេងៗទៀត គឺគ្រឿងសម្រាប់ប្រើក្នុងការទទួលទានអាហារ ដូចជាប្រើប្រាស់សម្រាប់ដាក់បាយទឹក គ្រឿងហិបស្លានិងប្រអប់សម្រាប់ដាក់វត្ថុផ្សេងៗ និងគ្រឿងរណ្តាប់ប្រើក្នុងកិច្ចពិធី។

### - គ្រឿងចានក្បាន

ជាទូទៅចានក្បានគេធ្វើពីដីដុត។ តែបើយោងតាមសិលាចារឹកនិងកំណត់ហេតុចិន យើងយល់ថាខ្មែរនិយមវត្ថុធ្វើពីលោហធាតុជាង។ សិលាចារឹកពុំបាននិយាយផ្ទាល់ពីចានក្បានសម្រាប់ដាក់បាយនិងម្ហូបអាហារទេ តែរៀបរាប់ពីគ្រឿងតង្វាយផ្សេងៗដែលទាយកទាយិកាថ្វាយដល់ប្រាសាទមួយចំនួនដូចជាផ្តិល ថូ ជន្ទាប់ កន្ថោរ។ល។ បើពិនិត្យមើលតាមបុរាណវត្ថុដែលនៅសេសសល់និងទិន្នន័យមានក្នុងសិលាចារឹក បញ្ជាក់ថាសិប្បកម្មលោហធាតុពេលនោះរីកចម្រើនខ្លាំង។ ហេតុដូច្នេះហើយបានជាលោក *Bernard Philip Groslier* ដែលធ្វើសេចក្តីសង្កេតក្នុងការសិក្សាពីកុលាលភាជន៍សម័យអង្គរ ហើយបានធ្វើការកត់សម្គាល់របស់គាត់ទៅលើវិស័យកុលាលភាជន៍ខ្មែរថាមិនសូវរីកចម្រើនខ្ពង់ខ្ពស់ដូចជាតិសាសន៍នៅក្បែរៗនេះ ដោយសារខ្មែរនិយមវត្ថុពីលោហធាតុជាង ហើយផលិតផលពីលោហធាតុមានកម្រិតសិល្បៈខ្ពស់ជាងកុលាលភាជន៍ឆ្ងាយណាស់។ បើយើងសង្កេតគ្រួសារខ្មែរដែលមានកម្រិតជីវភាពសាមញ្ញនៅតាមជនបទ សព្វថ្ងៃឃើញថាត្រឹមត្រូវតាមការអះអាងនេះមែន។ សព្វថ្ងៃ អ្នកស្រែចម្ការខ្លះនៅប្រើផ្តិលខាត់ (ផ្តិលធ្វើពីស្ពាន់) សម្រាប់ដាក់ទឹកទទួលទាន ឬក្នុងកិច្ចបុណ្យទានផ្សេងៗ (រូបលេខ២៨) ដណ្តាំបាយនឹងឆ្នាំងខ្វាន់ធ្វើពីស្ពាន់ (រូបលេខ២៩)។ មកដល់ទសវត្ស ១៩៦០ ការផលិតផ្តិលស្ពាន់មានសកម្មភាពមមាញឹកគួរសមដែរ ជាពិសេសនៅភូមិយោលទោង (ឃុំសុរភី ស្រុកបាទី ខេត្តតាកែវ) និងផ្សារដែក (ស្រុកពញាឮ

ខេត្តកណ្ដាល)[៤០]។ ក៏ប៉ុន្តែ នៅកោះចិនក៏មានធ្វើផ្តិលស្ពាន់ដែរ តែមានលក្ខណៈប្រណីតជាង និងមានក្បាច់ក្បូរផង (រូបលេខ១០)។ ជាទូទៅ តំបន់នេះគេធ្វើគ្រឿងប្រាក់។ រូបលេខ១១ដល់រូបលេខ១៩ ជាឧទាហរណ៍នៃគ្រឿងប្រាក់ដែលមានប្រើដល់បច្ចុប្បន្ន។



រូបលេខ៨៖ ផ្តិលខាត់។



រូបលេខ៩៖ ឆ្នាំងខ្វាន់។



រូបលេខ១០៖ ធ្វើផ្តិលស្ពាន់។



រូបលេខ១១៖ គ្រឿងប្រាក់ខ្លះៗនៅសម័យមុន
(រូបថត៖ ពេជជាងជួសជុលចម្លាក់ថ្មនៃសារមន្ទីរជាតិ ភ្នំពេញ)។

[៤០] *Delvert, Jean, 1994,* Le paysan cambodgien, *L'Harmattan, p.265-267.*





រូបលេខ១២



រូបលេខ១៣



រូបលេខ១៤



រូបលេខ១៥

រូបលេខ១២-១៩៖
គ្រឿងប្រាក់ខ្លះៗដែលមានដល់សព្វថ្ងៃ (រូបថតលេខ១៥ ជារបស់សារមន្ទីរជាតិ ភ្នំពេញ)។



រូបលេខ១៦



រូបលេខ១៧



រូបលេខ១៨



រូបលេខ១៩

ការផលិតគ្រឿងប្រាក់វិញ គេឃើញប្រមូលផ្តុំគ្នានៅភូមិមួយចំនួនក្បែរអតីតរាជធានីឧត្តុង្គ ពោលគឺតំបន់កំពង់ហ្លួងនិងកោះចិន។ គ្រឿងប្រាក់ទាំងនោះភាគច្រើនគេធ្វើតាមការបញ្ជាទិញពីអ្នកមានទ្រព្យសម្បត្តិនៅភ្នំពេញ។ ដោយសារប្រាក់ថ្លៃផង គេកម្រឃើញជាងប្រាក់មានវត្ថុធាតុដើមប្រាក់នៅតាមផ្ទះ ហើយផលិតជាគ្រឿងសម្រាប់ដាក់ទុកលក់ដូរដូចគ្រឿងស្ពាន់ឬដែកណាស់។ កាលណាគេត្រូវការគ្រឿងអ្វីមួយពីប្រាក់ អ្នកទាំងនោះមករកជាងដើម្បីស្នើឲ្យធ្វើ ដោយនាំ

យកប្រាក់មកផ្ទាល់ខ្លួន ឬផ្ទួលជាងមកធ្វើដល់ផ្ទះក៏មាន។ មិនដូចជាងស្ពាន់ ជាងស្មិត ឬជាងដែក ដែលធ្វើវត្ថុប្រើប្រាស់សម្រាប់មហាជនទូទៅទេ ជាងប្រាក់ច្រើនតែធ្វើវត្ថុប្រណីតៗសម្រាប់មនុស្សជាន់ខ្ពស់។ អាស្រ័យហេតុនេះ គេតែងឃើញជាងប្រាក់ផ្តុំគ្នានៅក្បែរៗទីប្រជុំជន ទីក្រុងធំៗ និងនៅក្បែរព្រះរាជវាំងទៀតផង។ បើពិនិត្យតាមកំណត់ហេតុរបស់លោកជីវ តាក្វាន់ និងសិលាចារឹកផ្សេងៗយើងឃើញថា ព្រះបរមរាជវាំង និងប្រាសាទ ឬអារាមផ្សេងៗជាទីដែលត្រូវការគ្រឿងប្រាក់ច្រើនជាងគេ។ បន្ទាប់មក ផ្ទះអភិជនជាមន្ត្រីធំ និងអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ មនុស្សក្នុងសង្គមជាន់ខ្ពស់ប្រើប្រាស់គ្រឿងប្រាក់ដើម្បីលើកយសសក្តិ។ ហេតុដូច្នេះគ្រួសារដែលមានជីវភាពល្មមៗក៏ខំខ្នះខ្នែងជាវគ្រឿងប្រាក់ខ្លះដាក់ផ្ទះ។ តាមភាពជាក់ស្តែង អ្នកស្រែមិនសូវប្រើគ្រឿងប្រាក់ប៉ុន្មានទេ ដោយសារមានតម្លៃថ្លៃ តែគេឲ្យតម្លៃខ្លាំងណាស់។ លោកជីវ តាក្វាន់បានរៀបរាប់ដូច្នេះថា៖

> «ពេលពិសាបាយ គេប្រើចានដីនាំចូលពីចិនឬចានស្ពាន់... គេផឹកស្រាដោយប្រើកែវធ្វើពីលោហធាតុ រីឯអ្នកក្រប្រើពែងធ្វើដីដុត។ មនុស្សទាំងអស់នៅក្នុងគ្រួសារអភិជន ពេលពិសាបាយ គេប្រើចានក្បានធ្វើពីប្រាក់ ជួនកាលរហូតដល់មាសផង។ ក្នុងឱកាសរាជពិធីលៀងសាយភោជន៍ គេប្រើចានក្បានធ្វើពីមាសយ៉ាងច្រើនសន្ធឹក ហើយដែលមានក្បូរក្បាច់យ៉ាងពិចិត្រ»[៤១]

បើយើងផ្ទៀងផ្ទាត់សិលាចារឹកឲ្យបានហ្មត់ចត់ យើងអាចដឹងខ្លះៗពីប្រភេទគ្រឿងប្រាក់ទាំងនោះបាន។ សិលាចារឹកទាំងនេះ គេចាររៀបរាប់ពីទ្រព្យសម្បត្តិនៃប្រាសាទ ឬតង្វាយដែលទាយកថ្វាយដល់ប្រាសាទនានា ក្នុងនោះមាននិយាយពីចានក្បានធ្វើពីមាស ប្រាក់ និងស្ពាន់ៗល។ គ្រឿងមាសប្រាក់ទាំងនោះខ្លះយើងនៅស្គាល់ត្រឹមតែឈ្មោះ មិនដឹងថាមានរូបរាងយ៉ាងណា ហើយខ្លះទៀតយើងថែមទាំងពុំធ្លាប់ឮឈ្មោះទៀតផង ក៏ប៉ុន្តែមួយចំនួនធំយើងនៅស្គាល់នៅប្រើ

៤១ *Zhou 1993, p. 59.*



និងផលិតដល់សព្វថ្ងៃ។ ឥឡូវយើងសូមលើកសិលាចារឹកនៃប្រាសាទព្រះឥន្ទ្រកោសីយ៍មកធ្វើជាឧទាហរណ៍ ដោយដកស្រង់ឃ្លាខ្លះនៃសិលាចារឹកបន្ទាត់ទី១ដល់៦ មកបង្ហាញដោយសម្រួលជាភាសាខ្មែរបច្ចុប្បន្ន[៤២]៖

> «នាថ្ងៃពេញបូណ៌មី ខែជេស្ឋ ឆ្នាំ៨៩០សក (គ.ស.៩៦៨) មានប្រសាសន៍ក្រោមល្អងធូលីជើងព្រះកម្រតេងអញ ប្រើធ្វើបញ្ជីទេវទ្រព្យ មានខ្ញុំ ភូមិករ ព្រះកម្រតេងអញ នាទ្វិជេន្ទ្របុរ ដែលប្រគល់ដល់ព្រះស្តេងកុលបតិ (ចៅអធិការប្រាសាទ?) មានមកុដជាំត្បូង១ ថ្នោង១ កន្ទាស់មានជាំត្បូង២ ក្រវិល២ ស័ង្ខ១ ចក្រ១ ដឹបង១ ដុំដី១ ប៉ានដៃដែលមានជាំគុជ១ អាវក្រោះធ្វើពីមាស១មានជាំត្បូង៩គ្រាប់ សម្លៀកបំពាក់១ កងដៃ៤ ចិញ្ចៀនជាំត្បូង៤ ចុរី១ កងជើង១។ គ្រឿងប្រាក់មានស្នាប់អាវក្រោះ ស្នាប់សម្លៀកបំពាក់ ស្នាប់ដឹបង ស្នាប់ស្រោបចំពួយ យោនី កញ្ចក់ (?)១ អាសនៈ១។ សង្វារមាស១ ខ្សែ(ក្រវាត់?) មានជាំត្បូង»

ក្រៅពីកំណត់ហេតុរបស់លោកជីវ តាក្វាន់ និងសិលាចារឹកទាំងនោះ នៅសម័យកណ្តាល យើងមានពត៌មានតិចតួចណាស់អំពីគ្រឿងប្រាក់ ជាពិសេសយើងដឹងតាមសេចក្តីរៀបរាប់ក្នុងរឿងព្រេង សាស្ត្រាល្បែងផ្សេងៗ។ នាសតវត្សទី១៩ ជនជាតិអឺរ៉ុបដំបូងៗដែលមកដល់ស្រុកខ្មែរចាប់អារម្មណ៍លើគ្រឿងប្រាក់ដែលលោកឃើញប្រើនៅក្នុងគេហដ្ឋានលោកចៅហ្វាយខេត្តសៀមរាប ហើយបានរៀបរាប់ដូចបានពោលម្តងហើយថា៖

> «...លោកចៅហ្វាយខេត្តបានបង្ហាញគ្រឿងហិបស្លាម្លូ និងគ្រឿងផ្សេងៗទៀត។ គាត់ប្រាប់យើងថា គ្រឿងទាំងនេះធ្វើដោយ

៤១ *Cœdès, G.,* Inscription du Cambodge III*, 1952, pp. 110.*

ជាងទងខ្មែរនៅខេត្តសៀមរាប ដោយរំលាយកាក់មាស និង ប្រាក់សុទ្ធយកមកពីក្រុងវេ (អាណាម)...»[៤៣]

រឿងព្រេងនិងសាស្ត្រាល្បែងតែងនិយាយលើកសរសើរពីទ្រព្យសម្បត្តិស្តុកស្តម្ភនៃព្រះមហាក្សត្រ អភិជន មន្ត្រី ឬសេដ្ឋីដែលជាតួអង្គក្នុងរឿងទាំងនោះ ដូចជារៀបរាប់ពីគ្រឿងប្រើប្រាស់ក្នុងវាំង ក្នុងវិមាន និងគេហដ្ឋានសេដ្ឋីទាំងនោះ ដែលសុទ្ធតែគ្រឿងមាសនិងប្រាក់។

ក្នុងសៀវភៅដែលមានចំណងជើងថា "បាត់ដំបងសម័យលោកម្ចាស់" របស់លោក តូច ឈួង ផ្តល់ពត៌មានច្រើនគួរសមពីគ្រឿងប្រាក់។ លោកបានរៀបរាប់ខ្លះពីជីវភាពទូទៅរបស់ប្រជាជននៅខេត្តបាត់ដំបងនាដើមសតវត្សទី២០ថា៖

> "...នៅសម័យសក្តិភូមិ ពួកអភិជនដែលមានមធ្យោបាយច្រើន ចូលចិត្តប្រើបរិក្ខារ ដូចជាអលង្ការ កន្ថោរ ផ្តិល ហិបស្លា ជើងពាន ធ្វើអំពីប្រាក់ឬមាស ដើម្បីលើកកិត្តិយសរបស់គេ...»[៤៤]

ដូច្នេះ ស្រទាប់ជាន់ខ្ពស់នៃសង្គម គេច្រើនប្រើភាជន៍ទាំងឡាយណាដែលធ្វើពីលោហធាតុផ្សេងៗ ដូចជាស្ពាន់ សំរិទ្ធិ បន្ទាប់មកលោហធាតុមានតម្លៃដូចជាប្រាក់។ ក្នុងករណីខ្លះធ្វើអំពីមាស ជាពិសេសនៅក្នុងវាំង។ ការប្រើប្រាស់វត្ថុធ្វើពីមាសអាចមានកំណត់តាមតំណែង និងក្នុងគោលបំណងលើកយសសក្តិមុខមាត់របស់អ្នកប្រើប្រាស់ឲ្យកាន់តែខ្ពង់ខ្ពស់ទៀតផង។

### - គ្រឿងហិបស្លា

គ្រឿងហិបស្លាធ្វើពីវត្ថុធាតុផ្សេងៗ។ អ្នកសាមញ្ញយកផ្តៅត្បាញជាកន្ត្រក ឬកំប្រោង បើអ្នកមានធនធានល្មមធ្វើពីឈើ ជួនកាលមានលាបម្រ័ក្សណ៍ ឬដាំខ្យង (រូបលេខ២០)។ ខ្លះទៀតធ្វើពីលោហធាតុផ្សេងៗ មានស្ពាន់ ប្រាក់ជាដើម

[៤៣] *Cf. Matic 2002: 2-3.*

[៤៤] តូច ឈួង (១៩៩៤) "បាត់ដំបងសម័យលោកម្ចាស់" ទ.៩២។



(រូបលេខ២១)។ បើមាសគឺមានតែនៅក្នុងវាំងប៉ុណ្ណោះ។ ហិបស្លាមានរូបរាងខុសៗគ្នា ខ្លះជាប្រអប់បួនជ្រុង ខ្លះប្រាំបីជ្រុង ខ្លះមូល ហើយតែងមានប្រអប់តូចៗផ្សេងទៀតនៅក្នុងនោះ គឺប្រអប់ស្លា ប្រអប់ថ្នាំចុក អកកំបោរ ជន្ទាប់ដាក់ក្រមួនលាបមាត់ និងស៊ិងជាដើម រីឯម្លូគេដាក់ក្នុងហិបនោះតែម្តង (រូបលេខ២២)។

កន្លងមកមានការសិក្សាច្រើនទាក់ទងនឹងទំនៀមទទួលទានម្លូស្លានេះ។ បើចង់ដឹងវែងឆ្ងាយ អ្នកអានអាចរកមើលសំណេរអំពីរឿងនេះ ត្បិតយើងនឹងមិនជជែកវែងឆ្ងាយនៅទីនេះទេ។ តែទោះបីយ៉ាងណា យើងមិនអាចជៀសមិន



រូបលេខ២០៖ ហិបស្លានិងគ្រឿងផ្សេងៗ។



រូបលេខ២១៖ គ្រឿងហិបស្លាធ្វើពីស្ពាន់។



រូបលេខ២២៖ ហិបស្លាធ្វើពីឈើ និងប្រអប់ប្រាក់។

និយាយមួយម៉ាត់ពីរនោះបានទេ។ ខ្មែរក៏ដូចជាតិសាសន៍ផ្សេងៗនៅអាស៊ីអាគ្នេយ៍ នៅឥណ្ឌា និងមួយផ្នែកនៃប្រទេសចិន មានទម្លាប់ទទួលទានម្លូស្លា។ ទំនៀមទទួលទានស្លានេះ ប្រហែលជាមានចំណាស់រហូតដល់សម័យបុរេប្រវត្តិផង។ សម័យចាស់ គេទទួលទានម្លូស្លាទាំងចាស់ទាំងក្មេង ទាំងប្រុសទាំងស្រី។ ការទទួលទានម្លូស្លានេះក្លាយជាសិល្បៈក្នុងការរស់នៅប្រចាំថ្ងៃផង និងបង្ហាញពីអំណាចក្នុងសង្គមផង។ ការទទួលទានម្លូស្លាក៏ក្លាយជារបៀបស្វាគមន៍រាក់ទាក់ទទួលភ្ញៀវ និងជាចំណងមិត្តភាព។ បើយើងពិនិត្យមើលតែក្នុង "ច្បាប់ស្រី" ដែលលើកដោយ ម៉ឺន មៃ នាសតវត្សទី១៧ មានទំនុកនិយាយយ៉ាងដូច្នេះ៖

"ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងធីស្លា"[៤៥]

ប្រពៃណីនេះមានតរៀងរហូតមក ហើយសំខាន់នៅក្នុងកិច្ចធ្ងន់វៃមួយចំនួនផង ដូចជាកិច្ចមួយក្នុងពិធីមង្គលការ។ ក្នុងការស្ដីដណ្ដឹងកំណត់មកថា ភាគីទាំងសងខាងដោះដូរស្លាគ្នាទទួលទានជាសញ្ញានៃការទទួលយល់ព្រមតាមពាក្យសុំស្ដីដណ្ដឹង។ កិច្ចនេះគេហៅថាស៊ីស្លាដូច្នេះតែម្ដង។ បើកិច្ចសំខាន់យ៉ាងដូច្នេះ ហិបស្លានិងគ្រឿងផ្សេងៗដែលនៅជាមួយក៏ត្រូវតែជាវត្ថុគាប់ភ្នែកនិងមានតម្លៃ (រូបលេខ២៣-២៤)។ ដូច្នេះ វត្ថុធាតុដែលគេយកមកធ្វើគ្រឿងទាំងនោះ បង្ហាញពីទ្រព្យសម្បត្តិ កម្រិតសង្គម វប្បធម៌ និងយសសក្តិនៃអ្នកម្ចាស់ទ្រព្យនោះផង។ ហេតុដូច្នេះហើយ បើជាអ្នកមានឬមន្ត្រីធំៗ គ្រឿងហិបស្លាតែងតែជាគ្រឿងប្រាក់។ ការទទួលទានម្លូស្លានៅអាស៊ីអាគ្នេយ៍ និងនៅស្រុកខ្មែរក៏ក្លាយជាវប្បធម៌នៃសង្គមជាន់ខ្ពស់។ ប្រអប់តូចៗមួយសម្រាប់ដែលមាននៅខាងក្នុងហិប មានដូចជាប្រអប់ស្លា ប្រអប់ម្លូ ប្រអប់គ្រឿងផ្សំមានសម្បកឈើឯមឬសម្បកសំព័រ អកកំបោរ ត្បាល់បុក សិង តែងតែធ្វើពីប្រាក់។ បើជាជនសាមញ្ញក៏គង់ធ្វើពីស្ពាន់និងមានក្បូរក្បាច់មើលទៅគាប់ភ្នែកដែរ។ អ្នកមាននិងអភិជននិយមប្រើគ្រឿងប្រាក់ដែល

[៤៥] ម៉ឺន មៃ ច្បាប់ស្រី "កម្រងល្បើក" មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ (១៩៨៨) ទ. ៩៩-១០០។






រូបលេខ២៣៖ កិច្ចក្នុងមង្គលការ។



រូបលេខ២៤៖ ស៊ីស្លាក្នុងមង្គលការ។

ធ្វើដោយជាងចំណានៗ។ ឯព្រះមហាក្សត្រនិងមជ្ឈដ្ឋានវាំង គេប្រើរបស់ដូចគ្នា តែធ្វើពីមាស។ ប្រអប់តូចៗ ដែលដាក់ក្នុងហិបមានរូបរាងផ្សេងគ្នា តែគេនិយមធ្វើជារូបសត្វ ផ្លែឈើ បើសាមញ្ញមានរាងមូល ឬជ្រុង តែប្រអប់នីមួយៗមានក្បូរក្បាច់ភ្ញីទេស (រូបលេខ២៥-៣០) ជួនកាលទៀតគេឆ្លាក់ជាតួអង្គផ្សេងៗក្នុងរឿងរាមកេរ្តិ៍ទៀតផង (រូបលេខ៣១-៣៣)។ បើជារូបសត្វ គេច្រើនធ្វើសត្វទាំង១២នៃឆ្នាំកំណើតរបស់មនុស្ស។ ជួនកាលគេធ្វើជារូបសត្វក្នុងទេវកថា ដូចជារាជសីហ៍ (រូបលេខ៣៤) គជសីហ៍។ ក្រៅពីសត្វតំណាងឆ្នាំទាំង១២ មានសត្វផ្សេងៗទៀតដែលនៅជិតស្និទ្ធនឹងជីវិតប្រចាំថ្ងៃរបស់គេ ដូចជាកង្កែប ត្រី រហូតដល់សត្វធំមានក្ដាន់ រមាំង ដំរីជាដើម (រូបលេខ៣៥-៤០)។ សត្វដំរីគេនិយមជាខ្លាំង ត្បិតគេជឿថាដំរីជាសត្វមានអំណាចហើយស្លូតបូតនិងត្រជាក់ត្រជុំ។ រូបរាងប្រអប់នេះធ្វើឲ្យយើងគិតថយក្រោយទៅដល់សម័យអង្គរ។ នៅសម័យអង្គរគេនិយមផលិតភាជន៍តូចៗ ជាប្រអប់ឬខួចជារូបរាងសត្វផ្សេងៗរបៀបនេះដែរ (រូបលេខ៤១)។ ភាជន៍


រូបលេខ២៥៖ ប្រអប់រូបផ្លែល្ពៅ។


រូបលេខ២៦៖ ប្រអប់រូបសត្វស្វាប។


រូបលេខ២៧៖ រូបសត្វអណ្ដើក។


រូបលេខ២៨៖ ប្រអប់មូល។


រូបលេខ២៩៖ ប្រអប់ប្រាំបីជ្រុង។


រូបលេខ៣០៖ ជន្ទាប់។




រូបលេខ៣១៖ ប្រអប់មាន ចម្លាក់តួអង្គក្នុងរឿងរាមកេរ្តិ៍។


រូបលេខ៣២៖ ប្រអប់មាន ចម្លាក់តួអង្គក្នុងរឿងរាមកេរ្តិ៍។


រូបលេខ៣៣៖ ប្រអប់មាន ចម្លាក់តួអង្គក្នុងរឿងរាមកេរ្តិ៍។


រូបលេខ៣៤៖ ប្រអប់រូប រាជសីហ៍។


រូបលេខ៣៥៖ ប្រអប់រូប កណ្ដុរ។


រូបលេខ៣៦៖ ប្រអប់រូប សត្វគ្រួច។


រូបលេខ៣៧៖ ប្រអប់រូបទា។


រូបលេខ៣៨៖ ប្រអប់រូបគោ។


រូបលេខ៣៩៖ ប្រអប់រូបដំរី។

ខ្លះ គេវិភាគមើលទៅឃើញថានៅមានជាប់កំបោរនៅផ្ទៃខាងក្នុង នាំឲ្យគេសន្និដ្ឋានថាពីមុនមកគេប្រើជាអកកំបោរ។ តឹកតាងទាំងនេះអាចឲ្យគេសន្និដ្ឋានថា យ៉ាងហោចណាស់ទំនៀមនៃការផលិតប្រអប់ប្រាក់រូបសត្វ ឬផ្លែឈើដែលយើងឃើញសព្វថ្ងៃនៅតំបន់កំពង់ហ្លួង មានដើមកំណើតតាំងពីពេលនោះមក។



រូបលេខ៤០៖ ប្រអប់រូបដំរី។



រូបលេខ៤១៖ អកកំបោរធ្វើពីដីដុត។

ប្រអប់ម្លូស្លាធ្វើពីមាស ឬប្រាក់ដែលត្រូវយកតាមខ្លួននេះ គឺក្លាយជាគ្រឿងសម្គាល់យសសក្តិ និងអំណាចទៀតផង។ ផ្ទាំងចម្លាក់ខ្លះដែលបង្ហាញពីទីសវនាការណាមួយ ឬក្នុងអាស្រមនៃព្រាហ្មណ៍ធំៗ គេឃើញមានភាជន៍ដែលមើលទៅសមជាគ្រឿងពានសម្រាប់ដាក់ម្លូស្លា (រូបលេខ៤២-៤៥) ហើយដែលនៅក្នុងវាំងគេហៅថា "ពានព្រះស្រី"។ ក្រោយមកគ្រឿងហិបស្លាជាគ្រឿងតំណាងយសសក្តិដែលត្រូវមានជាប់ខ្លួន ដូចជាកេតនភ័ណ្ឌនៃមន្ត្រីធំៗទៀតផង។ ទោះបីជាអ្នកប្រវត្តិសាស្ត្ររៀបរាប់ថា ពេលឡើងសោយរាជ្យ ព្រះបាទអង្គឌួងមាន



រូបលេខ៤២



រូបលេខ៤៣

រូបលេខ៤២-៤៥៖ ភាជន៍ដែលមានរូបរាងដូចជើងពានប្រាក់សព្វថ្ងៃ (រូបលេខ៤២-៤៣ ចម្លាក់នៅប្រាសាទបាយ័ន្ត ឯរូបលេខ៤៤-៤៥ ចម្លាក់នៅអង្គរវត្ត)។





រូបលេខ៤៤



រូបលេខ៤៥

សេចក្តីខ្វាយខ្វល់ខ្លាំងពីលទ្ធភាពដែលរៀបចំនគរខ្មែរឡើងវិញ ដោយសារស្រុកធ្លាក់ដុនដាបក្រខ្សត់ខ្លាំង តែពេលនោះក៏គេនៅតែចាត់ទុកគ្រឿងប្រាក់ថាសំខាន់ជាកិត្តិយស។ ក្រោយឡើងសោយរាជ្យសម្បត្តិ ព្រះបាទអង្គឌួងប្រកាសអនុញ្ញាតឲ្យភរិយាមន្ត្រីធំៗមានគ្រឿងប្រអប់ស្លាតាមខ្លួនដូចប្តីដែរ ពេលចូលវាំងគាល់ស្តេច ឬក្នុងសវនាការផ្សេងៗ[៤៦]។

## - គ្រឿងបូជា

ក្រៅពីចានក្បានដែលប្រើប្រាស់ប្រចាំថ្ងៃ យើងឃើញគេធ្វើគ្រឿងប្រាក់មួយចំនួនទៀតសម្រាប់តែប្រើក្នុងឱកាសបុណ្យទាន ឬជាគ្រឿងរណ្តាប់ក្នុងកិច្ចពិធីតែម្តង។ សូមកត់សម្គាល់ថា គ្រឿងរណ្តាប់ប្រាក់ទាំងនេះច្រើនតែធ្វើតាមគ្រឿងរណ្តាប់ជាក់ស្តែងដែលធ្វើពីរុក្ខជាតិ ឬវត្ថុធាតុអ្វីមួយដែលគេតែងធ្វើរាល់កិច្ចពិធីម្តងៗ។ តែគ្រឿងខ្លះគេអាចតម្កល់យូរពេញមួយឆ្នាំទល់មួយឆ្នាំ។ ទាយកទាយិកាដែលមានចិត្តជ្រះថ្លាក្នុងសាសនា គេធ្វើគ្រឿងរណ្តាប់ទាំងនោះពីប្រាក់ បើពីសម័យអង្គរផងមានរហូតដល់មាស។ ក្រៅពីគ្រឿងរណ្តាប់ គេធ្វើបដិមាទេពក្នុងព្រហ្មញ្ញសាសនាក្តី ក្នុងព្រះពុទ្ធសាសនាក្តីអំពីប្រាក់ឬមាសដែរ។

---

៤៦ អាដេម៉ា ឡឺក្លែរ ២០០៦ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា" មណ្ឌលឯកសារកម្ពុជា ទ.២៦៣ និងទ.៣៨៤។

នៅដើមឆ្នាំ១៩៨៣ គេធ្លាប់ប្រទះឃើញរូបព្រះគោនន្ទីមួយនៅទួលគុហារ (ស្រុកស្អាង ខេត្តកណ្ដាល) ដែលគេសន្និដ្ឋានថាសាងនៅសតវត្សទី៧ (រូបលេខ៤៦)។ រូបព្រះគោនន្ទីនេះសិតពីលោហធាតុ ដែលមានជាតិប្រាក់ប្រមាណជាង៧០ភាគរយ។ សព្វថ្ងៃរូបនេះតម្កល់នៅក្នុងហោព្រះត្រៃនៃព្រះបរមរាជវាំង។ សិលាចារឹកនៅក្រុមប្រាសាទសម្បូណ៌ព្រៃគុក (ខេត្តកំពង់ធំ) មានរៀបរាប់ថា គេសាងរូបព្រះគោធ្វើអំពីប្រាក់[៤៧]។ រូបព្រះគោនន្ទីដែលគេដឹងតាមសិលាចារឹកចារនៅប្រាសាទសម្បូណ៌ព្រៃគុកនិយាយថាជារូបស្នងឲ្យក្រឹតយុគ[៤៨]។ បើយើងស្រង់តែក្នុងសិលាចារឹកនៅប្រាសាទព្រះខ័ន ចារនៅគ.ស.១១៩១ រៀបរាប់ថា មានបដិមាធ្វើពីមាសនិងប្រាក់ចំនួន៤៣០ តម្កល់នៅប្រាសាទនេះ និងជាង២០០០០ទៀត នៅពាសពេញចក្រភពខ្មែរនាពេលនោះ[៤៩]។



រូបលេខ៤៦៖ រូបព្រះគោនន្ទីធ្វើពីប្រាក់ (រកឃើញឆ្នាំ១៩៨៣
នៅទួលគុហារ ស្រុកស្អាង ខេត្តកណ្ដាល)។

៤៧ *Bhattacharya, Kamaleswar, 1961,* Les religion brahmaniques dans l'ancien Cambodge, *Paris p. 88.*

៤៨ សូមអានខ្លឹមសារពិស្ដារក្នុងសៀវភៅរបស់លោក *Kamaleswar Bhattacharya, 1961* ដែលនិយាយខាងលើនេះ។

៤៩ *Cœdès, G., 1942,* BEFEO *41: 255-302.*

គ្រឿងប្រើក្នុងកិច្ចពិធីដែលយើងឃើញស្គាល់គ្រប់ៗគ្នា ជាពិសេសគ្រឿងប្រើក្នុងពិធីមង្គលការ។ សព្វថ្ងៃគ្រឿងរណ្ដាប់ក្នុងមង្គលការទាំងនេះ គេធ្វើពីស្ពាន់ ឬទង់ដែងជ្រលក់ប្រាក់ ជួនកាលរហូតដល់ពណ៌មាសទៀតផង ដោយសារសព្វថ្ងៃការជ្រលក់ពណ៌មាសឬប្រាក់នេះងាយ។ គ្រឿងរណ្ដាប់ដែលមានសក្ការៈខ្លាំង គេអាចធ្វើពីប្រាក់ឬរហូតដល់មាសផង។ អ្នកដែលមានទ្រព្យសម្បត្តិ ហើយមានសាទ្ធាជ្រះថ្លាក្នុងសាសនា ឬក្នុងជំនឿណាមួយក៏តែងធ្វើគ្រឿងរណ្ដាប់របៀបនេះជាតង្វាយដល់ប្រាសាទ វត្តអារាម និងទីតម្កល់ព្រះពុទ្ធរូបតាមផ្ទះ (រូបលេខ៤៧-៥៤)។ សិលាចារឹក K. 754 ដែលចារនៅសតវត្សទី១៤ និយាយពីស្បូវក្លាំងធ្វើពីប្រាក់ដែលគេធ្វើជាគ្រឿងរណ្ដាប់ថ្វាយដល់ប្រាសាទ[៥០]។ គេយកប្រាក់ចារយ័ន្ត្រ ធ្វើខ្សែគាថា និងឆ្លាក់ធ្វើគម្រុបក្រាំង គម្ពីរ សាស្ត្រាស្លឹករឹត។ល។



រូបលេខ៤៧៖ ព្រះពុទ្ធរូប និងដើមពោធិមាសនិងប្រាក់។



រូបលេខ៤៨៖ កោដ្ឋប្រាក់ជ្រលក់មាស។



រូបលេខ៤៩៖ ចេតិយកែវស្រោបបាក់ជ្រលក់មាស។

៥០ BEFEO *XXXVI, 17:19.*



រូបលេខ៥០៖ បល្ល័ង្កប្រាក់និង ព្រះពុទ្ធរូបស្រោបមាស។



រូបលេខ៥១៖ បល្ល័ង្កនិងព្រះពុទ្ធរូបធ្វើពីប្រាក់។



រូបលេខ៥២៖ ព្រះពុទ្ធទ្រង់បាត្រ។



រូបលេខ៥៣៖ ព្រះពុទ្ធរូបប្រាក់តាំងនៅ សារមន្ទីរជាតិភ្នំពេញ។



រូបលេខ៥៤៖ រូបព្រះវិហារប្រាក់តាំងនៅ សារមន្ទីរជាតិ ភ្នំពេញ។



## គ្រឿងប្រាក់ច្នៃបង្កើតថ្មី

ក្នុងផ្នែកនេះ យើងបានបែងចែកគ្រឿងប្រាក់តាមគោលពីរ គឺគ្រឿងប្រាក់ដែលផលិតតាមទំនៀមទម្លាប់តាំងពីបុរាណរៀងមក និងគ្រឿងប្រាក់ដែលបង្កើតថ្មីទៅតាមសម័យនិយម។ ក្នុងផ្នែកនេះ យើងនឹងពិនិត្យពីគ្រឿងប្រាក់បង្កើតថ្មី។ ចាប់ពីជំនាន់អាណាព្យាបាលបារាំងមក ការផលិតគ្រឿងប្រាក់ខ្មែរឈានចូលរបត់ថ្មីមួយ។ របត់ថ្មីនេះមានឡើងពេលដែលលោក *George Groslier* រៀបចំអតីតរោងជាងផ្សេងៗនៃព្រះរាជវាំងទៅជាសាលារចនា និងក្រោយមកក្លាយជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនេះឯង។ ពេលនោះ វិស័យចម្លាក់ប្រាក់ក៏ក្លាយជាផ្នែកមួយដែលត្រូវរៀនពេញលេញនិងមានកម្មវិធីត្រឹមត្រូវ។ លោក *George Groslier* បានជម្រុញឲ្យមានការបង្កើតគម្រូថ្មីៗបន្ថែមលើអ្វីដែលជាងខ្មែរចេះធ្វើតៗគ្នាស្រាប់។

គ្រឿងប្រាក់ដែលបង្កើតថ្មីពេលនោះ ផ្តើមចេញពីវត្ថុជាតម្រូវការនៃជនជាតិបារាំងដែលរស់នៅស្រុកខ្មែរនិងអភិជនខ្មែរ ត្បិតពេលនោះ របៀបរស់នៅតាមគម្រូលោកខាងលិចជាសញ្ញាបង្ហាញពីភាពខ្ពង់ខ្ពស់ និងទាន់សម័យនៃអភិជនខ្មែរ និងអ្នកមានទ្រព្យសម្បត្តិ។ គ្រឿងប្រាក់ដែលបង្កើតថ្មីទាំងនោះជាអាទិ៍មានស្លាបព្រាសម ប្រអប់បារីស៊ីហ្គា ប្រអប់ដែកកេស ប្រអប់ប្រេងម្សៅ បំពង់ដាក់កាបូសម្រាប់ហិត កាបូបដៃ (រូបលេខ៥៥-៦២)។ល។ សូមជ្រាបថា ស្លាបព្រាប្រហែលជាខ្មែរចាប់ប្រើនាសម័យថ្មីៗនេះទេ ពីមុនមកខ្មែរទទួលទានអាហារនឹងដៃ ដោយចាប់ម្ហូបក្នុងថាស ចាប់យកបាយពីស្មុកដែលមានគម្រប[៥១] ឬពីចានធ្វើពីលោហធាតុ ឬធ្វើពីដីដុត។ ចម្លាក់នៅប្រាសាទបាយ័ន្តដែលបង្ហាញពីពិធីលៀងសាយភោជន៍ធំដំមួយ យើងឃើញមនុស្សម្នាទទួលអាហារដោយដៃយ៉ាងដូច្នេះ។ បើជាសមវិញ យើងជឿថារហូតដល់សព្វថ្ងៃផ្ទះខ្មែរភាគច្រើនពុំមានប្រើឬពុំថ្មីកក្នុងការប្រើទៀតផង ត្បិតជាវត្ថុថ្មីណាស់ក្នុងចំណោមវត្ថុប្រើប្រាស់ក្នុងផ្ទះបាយខ្មែរ។ ពេលដែលខ្មែរចាប់និយមជក់បារី ពេលនោះប្រអប់បារីធ្វើពីប្រាក់ជានិមិត្តរូបនៃភាពខ្ពង់ខ្ពស់ និងទាន់សម័យ ដែលពីមុនជាគ្រឿងហិបស្លា។ ចាប់ពីពេលនោះមក ការ

---

៥០ *Groslier, B.P., 2000, p. 156.*

ប្រិតប្រៀងទៅលើគ្រឿងហិបស្លាក្នុងកិច្ចបដិសណ្ឋារកិច្ចក្នុងគ្រួសារក៏មិនដូចមុន ហើយបន្តិចម្តងៗ គ្រឿងហិបស្លាក៏ក្លាយជាវត្ថុដាក់តាំងវិញ។ ប៉ុន្មានទសវត្សរ៍ក្រោយមកទៀត គ្រឿងប្រាក់ថ្មីលេចឡើងជាបន្តបន្ទាប់ ខ្លះយកគម្រូតាមគ្រឿងប្រាក់ដែលផលិតដោយជាងប្រាក់ចិនរស់នៅស្រុកខ្មែរ។ សព្វថ្ងៃ ជាងខ្លះច្នៃគ្រឿងថ្មីតាមសេចក្តីត្រូវការទីផ្សារទេសចរដូចជាប្រអប់ដាក់ក្រដាស ប្រអប់ដាក់នាមប័ណ្ណ ស្រោបកែវ និងគ្រឿងប្រាក់បែបបុរាណ តែច្នៃជាគ្រឿងតាំងលម្អ ឬជាពានរង្វាន់ក្នុងការប្រលងស្នាដៃអ្វីមួយ ជាពិសេសក្នុងវិស័យកីឡា (រូបលេខ២៦៣)។



រូបលេខ៥៥៖ សមនិង ស្លាបព្រាប្រាក់។



រូបលេខ៥៦៖ ដបទឹកអប់ស្រោបប្រាក់។



រូបលេខ៥៧៖ ប្រអប់ម្សៅ។



រូបលេខ៥៨៖ ប្រអប់ម្សៅ។



រូបលេខ៥៩៖ បំពង់ដាក់កាបូហិត។





រូបលេខ២៦០៖ កាបូបប្រាក់។



រូបលេខ២៦១៖ កែវទឹកស្រោបប្រាក់។



រូបលេខ២៦២៖ ប្រអប់ដាក់នាមប័ណ្ណ។




រូបលេខ២៦៣៖ ពានរង្វាន់ធ្វើពីស្ពាន់ជ្រលក់ប្រាក់។

## ២. កាក់ប្រាក់

នៅលើពិភពលោកគេយកវត្ថុដូចជាសម្បកខ្យងឬលោហធាតុមួយចំនួនធ្វើជា "រូបិយវត្ថុ" សម្រាប់ដោះដូរទំនិញតាំងពីយូរលង់មកហើយ។ ចំពោះកាក់ជាទូទៅធ្វើអំពីមាសឬប្រាក់ តែជួនកាលគេធ្វើពីស្ពាន់ ទង់ដែង សំណប៉ាហាំង ដែកជាដើម។ គេផលិតកាក់ពីលោហធាតុដំបូងនៅរវាងឆ្នាំ៧០០-៦០០មុនគ.ស.[៤២]។ កាក់ទាំងនោះមានរូបរាងផ្សេងៗ ដូចជារាងមូលសំប៉ែត ខ្លះទៀតមានរាងជ្រុងទ្រវែង ឬជាសណ្ឋានសត្វអ្វីមួយ ឧទាហរណ៍ ប្រាក់ខ្លងដែលមានរាងដូចដង្កូវខ្លង

---

៤២ http://en.wikipedia.org/wiki/Silver

(រូបលេខ៦៤)។ ក្រោយមកទើបមានរូបិយប័ណ្ណធ្វើពីក្រដាសចេញមុខជំនួសកាក់ធ្វើពីលោហធាតុទាំងនោះ។ ទោះបីប្រាក់លែងជារូបធាតុសំខាន់សម្រាប់ការផលិតក្ដី ភាសាមួយចំនួនលើពិភពលោក ក្នុងនោះមានភាសាខ្មែរផងក៏នៅតែហៅថា "ក្រដាសប្រាក់" ដដែល។



រូបលេខ៦៤៖ ប្រាក់ខ្នងដែលម្ចាស់យកមកផ្សាច្នៃជាក្រវិលពាក់។

កម្ពុជាក៏ដូចជាប្រទេសផ្សេងៗទៀតនៅអាស៊ីអាគ្នេយ៍ដែរ អ្នកស្រាវជ្រាវដឹងថាតំបន់នេះមានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិយ៉ាងសកម្មតាំងពីមុនគ្រិស្តសករាជមកម្ល៉េះ។ ពាណិជ្ជកម្មអន្តរជាតិនេះហើយដែលនាំឲ្យកម្ពុជាពេលនោះស្គាល់ការរីកចម្រើន ដែលពុំធ្លាប់មានពីសម័យបុរេប្រវត្តិ។ តំបន់មួយចំនួននៅចន្លោះឈូងសមុទ្រសៀម និងឧបទ្វីបម៉ាឡាយូក្លាយជាទីសំចតនាវាដែលធ្វើដំណើរចុះឡើងពីចិនទៅឥណ្ឌា ព្រមទាំងប្រទេសក្នុងតំបន់មានចាម្ប ជ្វាជាដើម។ នាវាទាំងនោះអាចធ្វើដំណើរតាមរបបខ្យល់រដូវ បន្តទៅឆ្ងាយដល់តំបន់អាស៊ីកណ្ដាល តំបន់មេឌីទែរ៉ាណេ និងចក្រភពរ៉ូម៉ាំង ដោយផ្ទាល់ក្ដីឬដោយប្រយោលក្ដី។ ភស្តុតាងនៃពាណិជ្ជកម្មអន្តរជាតិរវាងតំបន់ធំៗទាំងពីរនេះ គួសបញ្ជាក់យ៉ាងច្បាស់តាមរយៈវត្តមាននៃកំពង់ផែសមុទ្រនៅអូកែវស្ថិតនៅដែនដីសណ្ដទន្លេមេគង្គ សព្វថ្ងៃនៅក្នុងខេត្តឡុងសៀង (វៀតណាម) និងកំពង់ផែមួយចំនួនទៀតនៅតាមបណ្ដោយសមុទ្រនៅភាគខាងត្បូងនៃទឹកដីថៃឡង់ដ៍បច្ចុប្បន្ន។ បុរាណវត្ថុមួយចំនួនដែលគេប្រទះឃើញតាមស្ថានីយ៍ទាំងនោះបូកផ្សំនឹងសំណេរផ្សេងៗនៃពង្សាវតារចិនបង្ហាញថា ពាណិជ្ជកម្មពេលនោះសកម្មណាស់។ កត្តានេះនាំឲ្យយើងសង្ស័យពីរបៀបដោះដូរទំនិញទាំងនោះថា តើគេធ្វើតាមរបៀបណា? នេះជាសំណួរដែលមានការជជែកវែងឆ្ងាយនៅឡើយ។ យើងសូមនិយាយពីកាក់បុរាណនេះបន្តិច។ នៅឆ្នាំ១៩៤៧ លោក *Louis Malleret* បានដឹកនាំការស្រាវជ្រាវបុរាណវិទ្យាដ៏ហ្មត់ចត់និងទូលំទូលាយមួយនៅអូកែវ។ កំណាយនោះគេប្រទះឃើញគ្រឿងសំណង់បុរាណនិងបុរាណវត្ថុមួយចំនួន។ វត្ថុក្នុងចំណោមនោះ ខ្លះមានប្រភពមកពីចិន ឥណ្ឌា ពិភពអារ៉ាប់ និងចក្រភពរ៉ូម៉ាំង។ តែអ្វីដែលគួរឲ្យចាប់អារម្មណ៍សម្រាប់ករណីសិក្សានេះ គឺវត្ថុធ្វើពីមាសនិងប្រាក់។ គេប្រទះឃើញមេដាយមាសនិងកាក់រ៉ូម៉ាំងមួយចំនួនដែលមានរូបអធិរាជ *Antonio Pius*។ ក្រៅពីនេះ គេឃើញមានកាក់ច្រើនប្រភេទផ្សេងទៀតដែលមានត្រាផ្សេងៗ និងមានអក្សរទេវនាគរី (រូបលេខ៦៥-៦៨)។ កំណាយនៅអង្គរបុរីក្នុងខេត្តតាកែវ ដែលជាក្រុងមួយក្នុងសម័យកាលជាមួយគ្នានឹងអូកែវ ហើយដែលនៅមិនឆ្ងាយពីអូកែវនិងទំនាក់ទំនងគ្នាយ៉ាងសំខាន់តាមព្រែកដែលគេជីកភ្ជាប់ពីសមុទ្រមកដែនដីខាងក្នុង គេក៏ប្រទះឃើញកាក់ប្រាក់ និងអលង្ការប្រភេទដូចគ្នាខ្លះ (រូបលេខ៦៩)។ ភស្តុតាងទាំងនេះបញ្ជាក់ថាយ៉ាងហោចណាស់អាណាចក្រហ្វូណនបានស្គាល់ប្រព័ន្ធពាណិជ្ជកម្មទ្រង់ទ្រាយធំរួចមកហើយ។ ទន្ទឹមនឹងនេះ គេស្គាល់យ៉ាងប្រាកដថាអ្វីជារូបិយវត្ថុដែលគេប្រើសម្រាប់ទូទាត់ទំនិញរួចមកហើយ ទោះបីជាយើងពុំដឹងថាអាណាចក្រហ្វូណនមាន ឬពុំទាន់មានរូបិយវត្ថុរបស់ខ្លួនក្ដី។



រូបលេខ៦៥ រូបលេខ៦៦ រូបលេខ៦៧ រូបលេខ៦៨

រូបលេខ៦៥-៦៨៖ ឧទាហរណ៍ខ្លះពីកាក់ប្រាក់ដែលប្រទះឃើញនៅអូកែវ។



រូបលេខ៦៩៖ កាក់ប្រាក់ប្រទះឃើញនៅអង្គរបុរី។